00172935

CMI/54

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ**

សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០១)

**អង្គបុរេជំនុំជម្រះ**

**ចំពោះមុខ:** ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នេយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 21 / 03 / 2008
ម៉ោង (Time/Heure): 15:55'
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: NUP SOTHUN VICHET

**ក្រឡាបញ្ជីសវនាការ** កែវ ម៉ានី
Dirk Jan LAMAN

**កាលបរិច្ឆេទ:** ២០ មីនា ២០០៨

---

# សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទ នួន ជា

---

**ការិយាល័យសហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT

**ជនត្រូវចោទ**
នួន ជា

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
លោក ហុង គឹមសួន
លោក ឡោ ជុនធី
លោក នី ចាន់ឌី

**សហមេធាវីការពារក្តី**
លោក សុន អរុណ
Michiel PESTMAN
Victor KOPPE

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 24 / 03 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

C11/54

**អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អ.វ.ត.ក"** ទទួលបានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលោក នួន ជា ។

**ជំពូក ១ - សេចក្តីផ្តើម**

១. អង្គបុរេជំនុំជម្រះ យោងទៅលើរបាយការណ៍ស្តីពីការត្រួតពិនិត្យ អនុម័តកាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៨ លើនីតិវិធី អង្គច្បាប់ និងអង្គហេតុក្នុងសំណុំរឿងនេះ ដែលជាផ្នែកមួយនៃសាលដីកានេះ។

២. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៧ អង្គបុរេជំនុំជម្រះបានចេញដីកាកំណត់ថ្ងៃបើកសវនាការ គឺថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៨។ អង្គជំនុំជម្រះបានលើកពេលធ្វើសវនាការទៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៨វិញ បន្ទាប់ពីមានសំណើមួយសុំឱ្យពន្យារពេលធ្វើសវនាការ ដើម្បីឱ្យសហមេធាវីអន្តរជាតិអាចចូលរួមការពារលោក នួន ជា ("ជនត្រូវចោទ")បាន។

៣. នៅថ្ងៃទី០៧ និង០៨ ខែកុម្ភៈ ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះ បានបើកសវនាការមួយផ្នែក*ជាសម្ងាត់* និងមួយផ្នែកទៀតជាសាធារណៈ។ ក្នុងអំឡុងពេលនៃសវនាការទាំងនេះ សហមេធាវីជាតិ និងសហមេធាវីអន្តរជាតិមួយរូបទៀតបានធ្វើជាតំណាងឱ្យជនត្រូវចោទ។

៤. មុនពេលសវនាការ អង្គបុរេជំនុំជម្រះ បានទទួលសំណុំរឿងដែលបានធ្វើបច្ចុប្បន្នភាព។

៥. នៅពេលចាប់ផ្តើមសវនាការកាលពីថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៨ សហមេធាវី បានលើកឡើងអំពីបញ្ហាការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងពេលសវនាការនេះ។ អង្គបុរេជំនុំជម្រះ បានសម្រេចអនុញ្ញាតឱ្យដាក់សារណាជាលាយលក្ខណ៍អក្សរបន្ថែមទៀតលើបញ្ហានេះ

អង្គបុរេជំនុំជម្រះ
E.C.C.C. C.E.T.C.
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ហើយអង្គបុរេជំនុំជម្រះនឹងធ្វើការសម្រេចលើបញ្ហានេះក្នុងសាលដីកាដាច់ដោយឡែកមួយ មុនសម្រេចសេចក្តីលើបណ្តឹងឧទ្ធរណ៍។ [១]

៦. អង្គបុរេជំនុំជម្រះបានសម្រេចក្នុងសាលដីកាដាច់ដោយឡែកមួយដែលបដិសេធការស្នើសុំរបស់សហមេធាវី អំពីញ្ញាការការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី[2]។ អង្គជំនុំជម្រះយល់ឃើញថា ខ្លឹមសារសារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី **សេខ ច័ន្ទធារី** ដែលជាសេចក្តីថ្លែងការណ៍របស់ជនរងគ្រោះ មិនត្រូវបានយកមកពិចារណាក្នុងការសម្រេចលើបណ្តឹងឧទ្ធរណ៍នេះឡើយ។

៧. អង្គបុរេជំនុំជម្រះបានអនុញ្ញាតឱ្យសហមេធាវី ដាក់ជូននូវកំណត់ហេតុដែលបានរៀបចំធ្វើឡើងដោយផ្នែកគាំពារការការពារក្តីអំពីការជួបជាលើកដំបូងជាមួយជនត្រូវចោទ បន្ទាប់ពីសវនាការ។ សេចក្តីសម្រង់កំណត់ហេតុដែលមានការដកចេញនូវព័ត៌មានមួយចំនួន ត្រូវបានដាក់ជូនមក ហើយបានដាក់ចូលក្នុងសំណុំរឿងនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៨។ នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះពិចារណាក្នុងការចេញដីកាបង្គាប់ឲ្យដាក់ជូនមកនូវកំណត់ហេតុដើមទាំងស្រុង [3]។ សំណើនេះត្រូវបានបដិសេធ។

---

[១] ជនត្រូវចោទ នួន ជា, សេចក្តីជូនដំណឹងស្តីពីការដាក់សារណាអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន និង ការអញ្ជើញអ្នកដែលមិនមែនជាភាគី, ១២ កុម្ភៈ ២០០៨ ( សំណុំរឿង: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ០១), C11/36

[2] សាលដីកាលអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ជំទាស់ការឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទ **នួន ជា** នៅថ្ងៃទី ២០ ខែមីនា ឆ្នាំ២០០៨_(សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០១) )

[3] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចុះនៅថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០០៨ ស្តីពីការលុបចេញនូសម្រង់កំណត់ហេតុដែលបានដាក់ដោយសហមេធាវីរបស់ជនត្រូវចោទ **នួន ជា** នៅថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០០៨_(សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០១) លេខ C11/46)

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C. ៣

## ជំពូក ២ - ភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍

៨. នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៧ សហមេធាវីជនត្រូវចោទ បានដាក់សេចក្ដីជូនដំណឹងអំពីការប្ដឹងឧទ្ធរណ៍។ តាមរយៈដីការបស់ក្រឡាបញ្ជីនាយកចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៧ អង្គបុរេជំនុំជម្រះបានអនុញ្ញាតឱ្យសហមេធាវីដាក់សារណាជាលាយលក្ខណ៍អក្សររបស់ខ្លួន ក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីទទួលបានសេចក្ដីជូនដំណឹងអំពីដីកានេះ។ ដីកានេះបានជូនដំណឹងដល់ជនត្រូវចោទនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៧ ។ សារណាបណ្ដឹងឧទ្ធរណ៍បានដាក់ជូនមកទាន់ពេលវេលា នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ ។

## ជំពូក ៣ - លក្ខណៈនៃបណ្ដឹងឧទ្ធរណ៍

៩. អង្គបុរេជំនុំជម្រះ នឹងពិនិត្យមើលឡើងវិញលើដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន (“ដីកា”) ដោយធ្វើការពិនិត្យទៅលើ៖

ក. នីតិវិធីរបស់សហចៅក្រមស៊ើបអង្កេតមុនពេលចេញដីកា។

ខ. ភាពគ្រប់គ្រាន់នៃអង្គហេតុក្នុងការចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ស្របតាមវិធានផ្ទៃក្នុង៦៣(៣)។

គ. ថាតើកាលៈទេសៈដែលដីកាបានយកមកធ្វើជាសំអាង នៅតែមាននាពេលបច្ចុប្បន្ននេះដែរឬទេ។ និង

ឃ. ការអនុវត្តឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ដោយគោរពទៅតាមវិធានផ្ទៃក្នុង ៦៣(៣)។

១០. ក្នុងអំឡុងពេលសវនាការ សហមេធាវីបានលើកអំពីសញ្ញាណជាមូលដ្ឋាននៃការជំនុំជម្រះប្រកបដោយយុត្តិធម៌ដែលក្នុងការអនុវត្តជាក់ស្ដែង ទំនងជាត្រូវបានមើលរំលង ឬមិនត្រូវបានយកចិត្តទុកដាក់ក្នុងកិច្ចដំណើរការនីតិវិធីមួយចំនួននៅចំពោះមុខអង្គបុរេជំនុំជម្រះ។ សហមេធាវី បាននិយាយសំដៅទៅលើល្បឿននៃការបដិសេធបណ្ដឹងជិតចិត្តចៅក្រមម្នាក់ក្នុងរឿងក្ដីនេះ និងសាលដីកាលើបណ្ដឹងឧទ្ធរណ៍ក្នុងរឿងក្ដីរបស់ កាំង ហ្កេកអ៊ាវ ។ សហមេធាវីលើកឡើងថា សាលដីកានោះហាក់ដូចជាបង្ហាញឱ្យឃើញនូវសំអាងហេតុសមហេតុសមផល និងអាចយល់បានពេញលេញ ប៉ុន្តែការយល់ឃើញលើអង្គហេតុមួយចំនួនដែលសហមេធាវី

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

00172939



បានបញ្ជាក់ហាក់ដូចជាស្នើឡើងថា គំនិតដោះស្រាយលើបញ្ហាសំខាន់ៗក្នុងរឿងក្តីនោះត្រូវបានបង្កើតឡើងរួចជាស្រេច។[4] សហមេធាវីបានជំរុញបន្ថែមទៀត ឱ្យអង្គបុរេជំនុំជម្រះគោរពគោលការណ៍សន្មតទុកជាមុន នៃភាពគ្មានទោស។

១១. ទាំងសវនាការតទល់គ្នា ទាំងឱកាសក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេច ផ្តល់លទ្ធភាពឱ្យជនត្រូវចោទសុំឱ្យ "តុលាការ" ត្រួតពិនិត្យឡើងវិញអំពីភាពត្រឹមត្រូវតាមផ្លូវច្បាប់ចំពោះការឃុំខ្លួន ដែលជាសិទ្ធិមួយមានចែងក្នុងមាត្រា៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ("ICCPR")[5]។ លើសពីនេះទៅទៀត មាត្រា៩ នៃកតិកាសញ្ញាអន្តរជាតិនេះ តម្រូវឱ្យធ្វើការពិនិត្យលើភាពត្រឹមត្រូវតាមច្បាប់ "ដោយគ្មានការពន្យារពេលឡើយ"។ អាស្រ័យហេតុនេះ ពុំបានយល់អំពីរបៀបដែលសហមេធាវីអាចសន្និដ្ឋានថា ល្បឿននៃការធ្វើសេចក្តីសម្រេចនាំឱ្យមានការមិនយកចិត្តទុកដាក់ ឬការមើលរំលងដល់សញ្ញាណជាមូលដ្ឋាននៃការជំនុំជម្រះប្រកបដោយយុត្តិធម៌នោះឡើយ។

១២. ការស្វែងរកការពិតដែលបានលើកឡើងដោយសហមេធាវី ក្នុងរឿងក្តីលើកមុនដែលអង្គបុរេជំនុំជម្រះបានសម្រេចនោះ គឺមានការពាក់ព័ន្ធនឹងភស្តុតាងដែលបានផ្តល់ឱ្យ និងជំហររបស់ជនត្រូវចោទក្នុងរឿងក្តីនោះ ។ ការសម្រេចសេចក្តីលើអង្គហេតុក្នុងរឿងក្តីមួយ ពុំអាចយកមកប្រើប្រាស់ដើម្បីសម្រេចសេចក្តីក្នុងរឿងក្តីមួយទៀតបានទេ ។ សហមេធាវីបានសន្និដ្ឋានទៅលើអង្គហេតុដែលបានសម្រេចនៅក្នុងរឿងក្តីពីមុន ដោយពុំបានយោងទៅលើសំអាងរបស់អង្គបុរេជំនុំជម្រះឡើយ ហើយការសន្និដ្ឋានដូច្នេះ ពុំបានបង្ហាញពីបិរបទនោះឡើយ ។ រឿងក្តីនិមួយៗនៅចំពោះមុខអង្គបុរេជំនុំជម្រះ ត្រូវសម្រេចតាមភស្តុតាងដែលមាននៅក្នុងរឿងក្តីនោះ។ នៅក្នុងរឿងក្តីនេះ អង្គបុរេជំនុំជម្រះនឹងធ្វើការស្វែងរកការពិត តាមរយៈការពិនិត្យ

---

[4] សហមេធាវីបានលើកឡើងថា សេចក្តីសម្រេចក្នុងរឿងក្តីរបស់កាំង ហ្គេកអ៊ាវ មានការរកឃើញជាក់ស្តែងមួយចំនួនដូចខាងក្រោម៖ "សាក្សីនៅរស់[ពីមន្ទីរស-២១]ទាំងអ្នកទោស ទាំងបុគ្គលិក ត្រូវគេលើកឡើងទាក់ទងនឹងរបបយង់ឃ្នង់គួររន្ធត់"(កថាខណ្ឌ៣២)។ "ជនត្រូវចោទបានទទួលស្គាល់ជាសាធារណៈតាំងពីឆ្នាំ១៩៩៩ ថា គាត់គឺជាប្រធានមន្ទីរសន្តិសុខស-២១ ជាកន្លែងដែលបុរស ស្ត្រី និងកូនក្មេងរាប់ពាន់នាក់ ត្រូវបានគេឃុំឃាំង ធ្វើទារុណកម្ម និងសំលាប់ចោល"(កថាខណ្ឌ៥៤)។ "ប្រជាជនកម្ពុជាមួយភាគធំសព្វថ្ងៃនេះពុំគ្រាន់តែបានឋិតនៅក្រមរបបដ៏យង់ឃ្នង់របស់ខ្មែរក្រហមប៉ុណ្ណោះទេ ប៉ុន្តែពួកគាត់ថែមទាំងមានសាច់ញាតិ ឬមិត្តភ័ក្តិរបស់ខ្លួនបានបាត់បងជីវិតម្នាក់ ឬច្រើនផងដែរ។" (កថាខណ្ឌ៥៥)។

[5] មាត្រា ៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៦៦ ។

មើលភស្តុតាងដែលបានបង្ហាញ និងជំហររបស់ជនត្រូវចោទ ហើយនឹងភាគីផ្សេងទៀតចំពោះភស្តុតាងនេះ។ ហេតុដូច្នេះ ពុំមានសេចក្តីសន្និដ្ឋានណាមួយដែលថាសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ នឹងត្រូវបានមើលរំលង ឬមិនយកចិត្តទុកដាក់ ដោយការសម្រេចជាមុនលើអង្គហេតុនោះទេ។

**ជំពូក ៤ - ការពិនិត្យលើនីតិវិធីរបស់សហចៅក្រមស៊ើបអង្កេត មុនពេលចេញដីកា**

១៣. យោងតាមវិធាន៦៣(១)នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតអាចចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទក្រោយពេលមាន“សវនាការតទល់គ្នា”។ វិធានផ្ទៃក្នុង៦៣(១) ចែងថា៖

> សហចៅក្រមស៊ើបអង្កេតអាចសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ក្រោយពេលមានសវនាការតទល់គ្នា។ ប្រសិនបើជនត្រូវចោទមិនមានជំនួយពីមេធាវីណាមួយនៅឡើយទេ សហចៅក្រមស៊ើបអង្កេតត្រូវប្រាប់ជនត្រូវចោទអំពីសិទ្ធិមានមេធាវីការពារ ដូចមានចែងក្នុងវិធាន ២១-១(ឃ)។ ជនត្រូវចោទមានសិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន។ ក្នុងពេលសវនាការតទល់គ្នា សហចៅក្រមស៊ើបអង្កេតត្រូវស្តាប់សហព្រះរាជអាជ្ញា ជនត្រូវចោទ និងមេធាវីជនត្រូវចោទ។ នៅពេលបញ្ចប់សវនាការតទល់គ្នា សហចៅក្រមស៊ើបអង្កេតត្រូវសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទត្រូវបានដោះលែងឱ្យមានសេរីភាព។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតសម្រេចឃុំខ្លួនបណ្តោះអាសន្ន សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាបង្គាប់ឱ្យឃុំខ្លួន[6]។

១៤. សំណួរមួយដែលបានលើកឡើងក្នុងបណ្តឹងឧទ្ធរណ៍ គឺថាតើការសម្រេចចិត្តរបស់ជនត្រូវចោទក្នុងការបន្តធ្វើសវនាការតទល់គ្នាដោយគ្មានជំនួយពីមេធាវី អាចចាត់ទុកថាជាការលះបង់ដោយ ស្របច្បាប់នូវសិទ្ធិទទួលបានជំនួយការច្បាប់ដែរឬទេ។

១៥. យោងតាមកំណត់ហេតុរបស់សហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះកត់សំគាល់ឃើញថា សហមេធាវីជនត្រូវចោទ និងសហព្រះរាជអាជ្ញាមាន ការបកស្រាយខុសគ្នាអំពីអង្គហេតុទាក់ទងនឹងការលះបង់សិទ្ធិរបស់ជនត្រូវចោទក្នុងកំឡុងការបង្ហាញខ្លួនលើកដំបូងនិងសវនាការ

[6] វិធាន៦៣ (១) នៃផ្ទៃក្នុង (វិសោធនកម្មលើកទី១) នៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០០៨

00172941

C11/54

តទល់គ្នា ។ ក្នុងកំឡុងពេលសវនាការ*សម្ងាត់* អង្គបុរេជំនុំជម្រះ បានពិនិត្យមើលផ្នែកជាច្រើននៃការថតវីដេអូអំពីការបង្ហាញខ្លួនលើកដំបូងនេះ និងសវនាការតទល់គ្នា ដែលទាក់ទងនឹងការលះបង់សិទ្ធិនេះ[៧]។ អង្គបុរេជំនុំជម្រះបានឃើញថា ទាំងការការបកស្រាយអំពីហេតុការណ៍ដោយភាគី ទាំងកំណត់ហេតុ ពុំបានផ្ដល់រូបភាពបានពេញលេញនូវអ្វីកើតឡើងពិតប្រាកដក្នុងបរិបទនេះ[៨]។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ បានផ្អែកលើការថតវីដេអូដែលបានចាក់បញ្ចាំងមើលក្នុងតុលាការ និងប្រតិចារឹកនូវអ្វីដែលបានស្ដាប់ឮតាមរយៈការបកប្រែក្នុងកំឡុងពេលសវនាការ[៩]។ អង្គបុរេជំនុំជម្រះ នឹងប្រើប្រាស់ព័ត៌មាននេះជាភស្តុតាង ដែលបានកើតឡើងក្នុងកំឡុងពេលសវនាការ ដើម្បីយកមកធ្វើការសម្រេចលើភាពត្រឹមត្រូវក្នុងការលះបង់សិទ្ធិ។

**ការបង្ហាញខ្លួនលើកដំបូង**

*យូ ប៊ុនឡេង* សួរ: ឥឡូវនេះ លោកមិនទាន់មានមេធាវីនៅឡើយទេ ? តើលោកចង់បានមេធាវីដែរឬទេ? នេះគឺជាសិទ្ធិរបស់លោក។

*នួន ជា* : ខ្ញុំសូមជម្រាបជូនលោកថា...

*អ្នកបកប្រែភាសាខ្មែរ-អង់គ្លេស:* អ្នកបកប្រែពិតជាមិនអាចស្ដាប់ឮទេ ពីព្រោះសម្លេងដើមមិនច្បាស់។ យើងនឹងព្យាយាមបកប្រែឱ្យអស់ពីសមត្ថភាព។

[អ្នកបកប្រែភាសាបារាំង-អង់គ្លេស ចាប់ផ្ដើមបកប្រែបន្ត]

*នួន ជា* : ប្រសិនបើតុលាការតម្រូវឱ្យខ្ញុំមានមេធាវី អញ្ចឹង...

*អ្នកបកប្រែបារាំង-អង់គ្លេស:* ស្ដាប់មិនឮទេ

[*អ្នកបកប្រែភាសាខ្មែរ-អង់គ្លេស* បកប្រែបន្ត]

---

[៧] សំណុំរឿង: 002/19-09-2007-ECCC/OCIJ, D20R និង C8R។

[៨] ជនត្រូវចោទ នួន ជា កំណត់ហេតុជាលាយលក្ខណ៍អក្សរអំពីការបង្ហាញខ្លួនលើកដំបូង ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ និងកំណត់ជាលាយលក្ខណ៍អក្សរអំពីសវនាការតទល់គ្នា ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ សំណុំរឿង: 002/19-09-2007-ECCC/OCIJ, D20 និង C8។

[៩] កិច្ចសន្ទនាពាក់ព័ន្ធត្រូវគេធ្វើប្រតិចារឹកបានយ៉ាងច្រើនតាមដែលធ្វើទៅបានពីភាសាកំណើតរបស់ជនត្រូវ[illegible] របស់អ្នកបកប្រែភាសាខ្មែរ។

00172942

C11/54

*យូ ប៊ុនឡេង:* នៅទីនេះ តុលាការមិនមានអ្វីបង្ខំលោកទេ។ ប្រសិនបើលោកពិតជាគិតថា លោកអាចការពារក្តីដោយខ្លួនលោកបាន អញ្ចឹងតុលាការមិនតម្រូវឱ្យលោកមានមេធាវីទេ។ ប៉ុន្តែប្រសិនបើលោកចង់បានមេធាវី អញ្ចឹងលោកអាចជ្រើសរើសមេធាវីបានតាមការជ្រើសរើសរបស់លោកបាន។ ឬ លោកអាចត្រូវការមេធាវីមួយរូប។ ប្រសិនបើលោកមិនមានលទ្ធភាពជួលមេធាវីទេ យើងមានសេវាត្រៀមរួចហើយសម្រាប់ផ្តល់ជូនលោក។

*នួន ជា* : ខ្ញុំបានជម្រាបលោករួចហើយអំពីមេធាវីខ្មែរ ហើយឈ្មោះរបស់គាត់បានស្នើរួចហើយ ប៉ុន្តែគាត់ឥឡូវនេះនៅខេត្តបាត់ដំបង។

*យូ ប៊ុនឡេង:* លោក សុន អរុណមែនទេ?

*នួន ជា* : បាទ! គាត់គឺជាមេធាវីខ្មែរ ប៉ុន្តែចំពោះមេធាវីបរទេស ខ្ញុំមិនស្គាល់ឈ្មោះ របស់គាត់នៅឡើយទេ។

*យូ ប៊ុនឡេង:* ដូច្នេះឥឡូវនេះចំពោះលោកសុន អរុណ។តើលោកចង់បានគាត់ឥឡូវនេះឬ?

*នួន ជា* : បាទ

*យូ ប៊ុនឡេង* សួរ: តើលោកបានជួបលោកសុន អរុណពីមុនមកទេ?

*នួន ជា* : យើងបានជួបគ្នា ប៉ុន្តែខ្ញុំមិនអាចចំណាំគាត់បានទេ

*យូ ប៊ុនឡេង:* អញ្ចឹងមានន័យថា លោកបានស្នើសុំគាត់ធ្វើជាមេធាវីរបស់លោករួចហើយ ហើយគាត់បាននិយាយថា គាត់អាចធ្វើជាមេធាវីរបស់លោក

*នួន ជា* : គាត់ពិតជាបាននិយាយថាគាត់នឹងមកនៅថ្ងៃស្អែក ឥឡូវនេះគាត់នៅខេត្តបាត់ដំបង។

*Marcel Lemonde*: ដូចនេះ បានសេចក្តីថា លោកបានជ្រើសរើសមេធាវីខ្មែរលោក សុន អរុណ ប៉ុន្តែសម្រាប់មេធាវីបរទេស លោកនឹងធ្វើការជ្រើសរើសនៅថ្ងៃក្រោយ។ តើលោកគិតយ៉ាងម៉េច? ដូច្នេះ ព្រោះថាលោកអាចនិយាយជាមួយមេធាវីជាតិដើម្បីធានាថាលោកអាចទាក់ទងជាមួយមេធាវីបរទេសបាន។ ប៉ុន្តែនៅទីនេះ យើងមានផ្នែកគាំពារការការពារក្តី ដែលអាចជួយលោកបាន។

*នួន ជា* : នៅពេលលោក សុន អរុណ មក។ ខ្ញុំនឹងពិភាក្សាជាមួយគាត់ ដូចនេះខ្ញុំអាចជ្រើសរើសផងដែរ នូវមេធាវីបរទេសមួយរូបសម្រាប់ការពាររឿងក្តីខ្ញុំ។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

*យូ ប៊ុនឡេង:* ដូចនេះមេធាវីខ្មែររបស់លោកគឺលោក សុន អរុណ និងលោកបាននិយាយថាលោកនឹងពិភាក្សាជាមួយលោក សុន អរុណ ដើម្បីជ្រើសរើសមេធាវីម្នាក់ទៀត ជាមេធាវីបរទេស។

*នួន ជា* ឆ្លើយ: ខ្ញុំគ្មានធនធានដើម្បីជួលមេធាវីម្នាក់ទេ។

**រូបភាពវីដេអូបង្ហាញថាចៅក្រម យូ ប៊ុនឡេង កំពុងតែនិយាយ**
**ប៉ុន្តែមិនមានការបកប្រែក្នុងអំឡុងពេលសវនាការ**

*យូ ប៊ុនឡេង:* សំណួរពាក់ព័ន្ធទៅនឹងបញ្ហាមេធាវី ខ្ញុំបានសួររួចហើយ។ ដូចនេះបន្ទាប់មក........ខ្ញុំបានជូនដំណឹងអំពីបទចោទរួចហើយ។ ហើយក្នុងកិច្ចដំណើរការនីតិវិធី នីតិវិធីទាំងអស់ត្រូវបានថតទុក។ ក្នុងកំឡុងពេលស៊ើបអង្កេតនឹងមានការសម្ភាសន៍ ដូចនេះនៅពេលដែលតុលាការសួរសំណួរ លោកមានសិទ្ធិមួយទៀតគឺសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ ប្រសិនលោកចង់មានយោបល់ឬសំណូមពរអ្វី លោកអាចធ្វើបាន។ ហើយលោកមានសិទ្ធិពិគ្រោះយោបល់ជាមួយមេធាវី។ ខណៈពេលដែលលោកគ្មានមេធាវីនៅជាមួយក្នុងទីនេះ យើងសូមបញ្ជាក់ឲ្យច្បាស់ថា ក្នុងពេលសម្ភាសន៍គ្រប់ពេល លោកអាចសុំទៅសហចៅក្រមស៊ើបអង្កេតឲ្យធ្វើការស៊ើបអង្កេត ឲ្យចេញដីកា ឬ ដីកាបង្គាប់ឲ្យនាំខ្លួន ឬ បំពេញកិច្ចស៊ើបអង្កេតណាមួយប្រសិនបើលោកយល់ឃើញថាមានសារៈសំខាន់ ។ នេះមានន័យថាក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី ប្រសិនបើលោកមានមេធាវី លោកអាចពិភាក្សាជាមួយមេធាវីរបស់លោកបាន។ ក្នុងករណីមួយចំនួនដែលលោកយល់ឃើញថាសំខាន់ចាំបាច់ លោកអាចស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតជួយប្រមូលយកភស្តុតាងដែលលោកចង់បាន។ សិទ្ធិទាំងនេះ ត្រូវបានការពារ និងបើតាមពិតទៅ ចៅក្រមគឺជាអ្នកសម្រេច។

*Marcel Lemonde*: ដោយហេតុតែមេធាវីរបស់លោកមិនមានវត្តមាននៅទីនេះ តើលោកចង់មានយោបល់ឬទេពាក់ព័ន្ធទៅនឹងបទចោទប្រឆាំងនឹងរូបលោក ឬអង្គហេតុប្រឆាំងនឹងរូបលោក?

*នួន ជា* : ខ្ញុំចង់មានយោបល់មួយចំនួនប្រឆាំងនឹងបទចោទទាំងនេះ។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

00172944

C11/54

*យូ ប៊ុនឡេង* សួរ: ខ្ញុំគិតថាប្រហែលជាមានការយល់ច្រឡំ ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ថា អម្បាញ់មិញនេះ ខ្ញុំបានប្រាប់លោកអំពីសិទ្ធិរបស់លោក។ ក្នុងពេលបង្ហាញខ្លួនលើកដំបូងនេះ និងនៅពេលចប់កិច្ចការនេះ ខ្ញុំនឹងប្រកាសនិងជូនដំណឹងអំពីព័ត៌មាន ឬលទ្ធភាពនៃការឃុំខ្លួនបណ្ដោះអាសន្ន ពីព្រោះក្នុងពេលបង្ហាញខ្លួនលើកដំបូងនេះ និងពេលនេះ លោកគ្មាន មេធាវីនៅជាមួយ ការបន្តកិច្ចដំណើរការនីតិវិធីនឹងសម្រេចថាតើលោកនឹងត្រូវឃុំខ្លួនឬអត់។ តើលោកចង់មានយោបល់អ្វីទេ ប្រសិនបើលោកគ្មានវត្តមានមេធាវីនៅជាមួយ។

*Marcel Lemonde*: ហេតុដូចនេះដោយសារយើងនឹងធ្វើសវនាការតទល់គ្នា តើលោកចង់មានយោបល់អ្វីទេ?

*នួន ជា* : ក្នុងពេលឥឡូវនេះ?

[*អ្នកបកប្រែភាសាបារាំង-អង់គ្លេស* បកប្រែ]

*Marcel Lemonde*: ប្រសិនបើលោកចង់មានយោបល់អ្វីមួយ នេះគឺជាពេលវេលាសម្រាប់លោក។ យើងនឹងថតកិច្ចការទាំងអស់នេះទុក។

[*អ្នកបកប្រែភាសាខ្មែរ-អង់គ្លេស* បកប្រែ]

*នួន ជា* : ខ្ញុំចង់មានយោបល់ក្នុងពេលឥឡូវនេះ។

*យូ ប៊ុនឡេង*: ដូចនេះក្រោយពេលលោកមានយោបល់ ចៅក្រមនឹងមានការពិភាក្សា នឹងមានសវនាការតទល់គ្នា ដើម្បីសម្រេចអំពី ឬ សម្រេចអំពីលទ្ធភាពនៃការឃុំខ្លួនបណ្ដោះអាសន្ន ។ ក្នុងករណីនេះតើលោកគិតថានឹងរង់ចាំរហូតដល់ពេលសវនាការតទល់គ្នានេះអាចធ្វើទៅបាន ឬលោកគិតថាសវនាការអាចធ្វើបានក្នុងពេលឆាប់ៗនេះ ឬក្នុងពេលប៉ុន្មាននាទីទៀត។

*នួន ជា* : បន្តអំពីបញ្ហាអ្វី?

*យូ ប៊ុនឡេង*: អម្បាញ់មិញនេះ លោកនិយាយថាលោកមានមេធាវីម្នាក់ ប៉ុន្តែគាត់មិនមានវត្តមាននៅទីនេះទេ។ ដូចនេះក្នុងកិច្ចដំណើរការនីតិវិធីបន្ទាប់ ក្រោយពេលការបង្ហាញខ្លួនលើកដំបូង នៅពេលលោកបានទទួលការជូនដំណឹងអំពីសិទ្ធិនិងបទចោទប្រកាន់នឹងរូបលោក បន្ទាប់មកយើងនឹងពិភាក្សាអំពីលក្ខខណ្ឌ ឬលទ្ធភាពនៃលក្ខខណ្ឌក្នុងការឃុំខ្លួន ដោយមានការចូលរួមពីសហព្រះរាជអាជ្ញាតាមការស្នើសុំ។ លោកអាចឆ្លើយតបបានចំពោះពួកគាត់ ប្រសិន

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

00172945

CMI154

បើលោកគ្មានមេធាវីទេ លោកក៏អាចឆ្លើយតបបានដែរ ឬប្រសិនបើលោកមានមេធាវី លោកក៏នៅតែអាចឆ្លើយបានដែរ។ ក្នុងស្ថានភាពនោះ ចៅក្រមនឹងធ្វើការសម្រេចអំពីលទ្ធភាព ក្នុងការឃុំខ្លួនបណ្ដោះអាសន្ន។ ដូច្នេះ តើលោកចង់រង់ចាំរហូតដល់ពេលលោកមានវត្តមាន មេធាវីនៅក្នុងទីនេះ ឬលោកចង់បន្តកិច្ចដំណើរការនីតិវិធីនេះ?

*នួន ជា* : ការពិតខ្ញុំចង់បន្តកិច្ចដំណើរការនីតិវិធីនេះដោយខ្លួនឯង។

*Marcel Lemonde*: ដូចនេះ ដើម្បីបញ្ជាក់ឱ្យច្បាស់ថែមទៀត លោកត្រូវបានជូនដំណឹងរួចហើយអំពីសិទ្ធិរបស់លោក។ ពីព្រោះ យើងនឹងមានសវនាការតទល់គ្នាដែលមានការចូលរួមពីសហព្រះរាជអាជ្ញានៃអ.វ.ត.ក និង លោកគួរតែដឹងថាលោកមានសិទ្ធិមានមេធាវី ហើយមេធាវីនោះនឹងអាចការពាររូបលោក។

*នួន ជា* : លោកចង់និយាយ ថាមេធាវី...សវនាការនឹងរៀបចំឡើងក្នុងរយៈពេល ២៤ ម៉ោង ឬក្នុងរយៈពេល ប៉ុន្មាននាទីទៀតនេះ។

*Marcel Lemonde*: នៅពេលដែលមេធាវីរបស់លោកមិនអាចចូលរួមបានក្នុងកិច្ច ដំណើរការនីតិវិធីក្នុងពេលនេះ មេធាវីអាចចូលរួមនៅទីនេះបាននៅថ្ងៃស្អែក។ ដូចនេះ ប្រសិនបើលោករង់ចាំរហូតដល់មេធាវីរបស់លោកមកចូលរួមក្នុងសវនាការ នោះសវនាការអាចរៀបចំឡើងបានតែនៅស្អែកប៉ុណ្ណោះ។

*នួន ជា* : ខ្ញុំមិនមានបញ្ហា ឬ ការសម្ងាត់អ្វីមួយដែលត្រូវលាក់បាំងនោះទេ។

*យូ ប៊ុនឡេង*: ដូចនេះ តើលោកប្រាកដហើយឬ? ពីព្រោះដើម្បីកុំឱ្យមានការភន្តច្រឡំ ដើម្បីកុំឱ្យមានការនិយាយថា តុលាការមិនបានប្រាប់លោកអំពីសិទ្ធិរបស់លោក ខ្ញុំសូមបញ្ជាក់ឱ្យច្បាស់ម្ដងទៀតថាចៅក្រមបានលើកឡើងរួចហើយថា យើងនឹងរៀបចំសវនាការតទល់គ្នាដោយមានការចូលរួមពីសហព្រះរាជអាជ្ញា និងលោកអាចឆ្លើយតបទៅនឹងពួកគាត់ជាមួយនឹងយោបល់របស់ខ្លួនផ្ទាល់ហើយ ប្រសិនបើលោកមានមេធាវី មេធាវីអាចជួយលោកផងដែរក្នុងការឆ្លើយតបនេះ។ ប្រសិនបើលោកយល់ថាយើងអាចរៀបចំសវនាការបានក្នុងពេលនេះដោយគ្មានវត្តមានរបស់មេធាវី នេះគឺជាសិទ្ធិរបស់លោក។ ហើយប្រសិនបើលោកត្រូវការមេធាវី ដូចនេះយើងត្រូវពន្យាពេលរហូតដល់ថ្ងៃស្អែក នៅពេលមានវត្តមានមេធាវី តុលាការអាចរៀបចំនីតិវិធីទៀតបាន។ ដូចនេះ ខ្ញុំចង់បញ្ជាក់ឱ្យបានច្បាស់ជាលើកចុងក្រោយថាតើសវនាការនេះ

PRE-TRIAL CHAMBER * E.C.C.C. * C.E.T.C. * CHAMBRE PRÉLIMINAIRE

ធ្វើក្នុងពេលឥឡូវនេះ ឬ យើងអាចរង់ចាំរហូតពេលមានវត្តមានរបស់មេធាវី ពីព្រោះលោកមិនមានមេធាវីទេក្នុងពេលនេះ។ សវនាការតទល់គ្នាអាចបន្តបានក្នុងពេលឥឡូវនេះ។

*នួន ជា* ឆ្លើយ: ខ្ញុំគិតថាយើងអាចធ្វើសវនាការតទល់គ្នាបានក្នុងពេលនេះ។ ប៉ុន្តែឥឡូវនេះខ្ញុំអាចធ្វើដោយម្នាក់ឯងបាន ទោះបីជាមេធាវីរបស់ខ្ញុំមិនមានវត្តមានក្នុងថ្ងៃនេះក៏ដោយ ខ្ញុំនៅតែចង់ឲ្យមានការពិភាក្សាគ្នា ក្នុងថ្ងៃនេះ។

**សវនាការតទល់គ្នា**

*យូ ប៊ុនឡេង:* សូមបន្តនីតិវិធី។ សមាសភាពរបស់ចៅក្រមចូលរួមក្នុងសវនាការនេះ ដូចខ្ញុំបានប្រាប់ហើយគឺមានខ្ញុំនិងលោកចៅក្រម *Marcel Lemonde*។ ឥឡូវនេះខ្ញុំសូមឧទ្ទេសនាមសមាសភាពថ្មីគឺលោកស្រី ជា លាង សហព្រះរាជអាជ្ញាជាតិ និងលោក *Robert Petit* សហព្រះរាជអាជ្ញាបរទេស។ សវនាការនេះគឺមានគោលដៅដើម្បីពិចារណាលើលទ្ធភាពក្នុងការឃុំខ្លួនបណ្ដោះអាសន្ន។ លោកបាននិយាយថាលោកមិនត្រូវការមេធាវីទេក្នុងថ្ងៃនេះ ហើយលោកអាចការពារខ្លួនដោយខ្លួនឯងបាន។ ហើយមេធាវីដែលលោកត្រូវការនឹងមកចូលរួមក្នុងកិច្ចដំណើរការនីតិវិធីនៅពេលក្រោយ។ ដូចនេះដើម្បីពិចារណាលើបញ្ហានេះ ខ្ញុំសូមប្រគល់ភារកិច្ចជូនទៅសហព្រះរាជអាជ្ញា ឲ្យបង្ហាញជូនពីសំណើឬសំណូមពរពាក់ព័ន្ធទៅនឹងលទ្ធភាពក្នុងការឃុំខ្លួនបណ្ដោះអាសន្ន។

*លោកស្រី ជា លាង:* អរគុណ ខ្ញុំសូមធ្វើការពន្យល់លើបញ្ហានេះ ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា។ ក្នុងនាមជាសហព្រះរាជអាជ្ញាយើងសូមមានពេលវេលាច្រើនទៀត ដើម្បីពិនិត្យមើលលើករណីនេះ។ ពីព្រោះសហព្រះរាជអាជ្ញាមិនបានចូលរួមតាំងតែពីដំបូងមក ដូចនេះក្នុងរយៈពេល៥នាទី សម្រាប់ធ្វើការជូនដំណឹង គឺជាពេលវេលាមួយដ៏ខ្លីក្នុងស្វែងយល់ឲ្យបានលម្អិតលើករណីនេះ។

ចំណុចទី២ យើងស្នើសុំឲ្យចៅក្រមជូនដំណឹងឲ្យបានច្បាស់លាស់ដល់ជនត្រូវចោទ អំពីសវនាការតទល់គ្នានេះ។ ពីព្រោះក្នុងកំណត់ហេតុ គាត់បាននិយាយថាគាត់ត្រូវការមេធាវីរបស់គាត់ ដូចមានឈ្មោះរួចហើយក្នុងកំណត់ហេតុនេះ។ នៅពេលគាត់បានយល់ដឹងហើយអំពីកិច្ចដំណើរការនីតិវិធីក្នុងសវនាការតទល់គ្នានេះ គាត់មិនត្រូវការមានមេធាវី។ ដូចនេះត្រូវបញ្ជាក់ឲ្យច្បាស់ថា គាត់យល់ដឹងអំពីបញ្ហានៃសវនាការតទល់គ្នានេះ ពីព្រោះសវនាការ

E.C.C.C. * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00172947

CA1154

គឺជាបញ្ហានៃការពិចារណាអំពីលទ្ធភាពក្នុងការឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទ។ ដូចនេះ គាត់អាចគិតថាតើគាត់ចង់មានមេធាវីឬក៏អត់ក្នុងពេលនេះ។ ដូច្នេះ នេះគឺជាសំណើរបស់សហព្រះរាជអាជ្ញា។ ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ថា គាត់ត្រូវបានជូនដំណឹងច្បាស់លាស់អស់ហើយ អំពីបញ្ហានៃសវនាការតទល់គ្នា និងអំពីសិទ្ធិរបស់គាត់ក្នុងការមានមេធាវី។ ពីព្រោះចៅក្រមនឹងចេញដីកាសម្រេចមួយ។

*យូ ប៊ុនឡេង:* ពីព្រោះតែសហព្រះរាជអាជ្ញាបានដាក់ជូននូវសំណើនេះ។ លោកនួន ជា បានបញ្ជាក់ច្បាស់រួចហើយ ក្រោយពេលការបង្ហាញខ្លួនលើកដំបូងនេះ។ លោកចៅក្រម *Marcel Lemonde* បានពន្យល់រួមម្ដងមកហើយអំពីសវនាការតទល់គ្នានេះ។ ហើយនិងអំពីផលវិបាកឬលទ្ធផលនៃលទ្ធភាព ក្នុងការសម្រេចពាក់ព័ន្ធទៅនឹងការឃុំខ្លួនបណ្ដោះអាសន្ន បញ្ហានេះបានបញ្ជាក់ជូនច្បាស់លាស់អស់ហើយ ជាពិសេសអំពីសិទ្ធិមានមេធាវី ឬអត់។ និងប្រសិនបើលោកត្រូវការមានមេធាវីនៅក្នុងទីនេះ បន្ទាប់មកចៅក្រមក៏បាននិយាយយ៉ាងច្បាស់ថាសវនាការតទល់គ្នានឹងអាចត្រូវពន្យាពេលដល់ថ្ងៃស្អែក។

ប៉ុន្តែលោកបាននិយាយយ៉ាងច្បាស់ថាលោកមិនត្រូវការមានមេធាវីទេ ពីព្រោះលោកអាចការពារបញ្ហាដោយខ្លួនឯងបាន។ ដូចនេះអ្វីដែលខ្ញុំបាននិយាយអម្បាញ់មិញនេះ គឺជាអ្វីដែលបានប្រាប់លោកមែនទេ?

*នួន ជា* ឆ្លើយ: ខ្ញុំមិនត្រូវការមានមេធាវីទេក្នុងពេលឥឡូវនេះ ប៉ុន្តែនៅថ្ងៃស្អែកមេធាវីរបស់ខ្ញុំមក។ ជាទូទៅ ខ្ញុំត្រូវការមេធាវី ប៉ុន្តែឥឡូវនេះមេធាវីរបស់ខ្ញុំមិនមានវត្តមាននៅទីនេះទេ។

*យូ ប៊ុនឡេង:* ពីព្រោះបញ្ហានេះពាក់ព័ន្ធទៅនឹងលទ្ធភាពនៃការឃុំខ្លួនបណ្ដោះអាសន្ន សូម្បីតែលោកចៅក្រម *Marcel Lemonde* ក៏បានបំភ្លឺបញ្ហានេះរួចអស់ហើយដែរ និងខ្ញុំក៏បានពន្យល់លោកផងដែរ តើលោកយល់បញ្ហានេះឬទេ? ដូចនេះខ្ញុំសូមពន្យល់លោកម្ដងទៀត ក្រោយពេលការបង្ហាញខ្លួនលើកដំបូង តើលោកត្រូវការមានមេធាវីឬ? ព្រោះក្នុងសវនាការតទល់ដែលនឹងត្រូវធ្វើ នឹងត្រូវពិចារណាទៅលើការឃុំខ្លួនបណ្ដោះអាសន្ន ។

នួន ជា: ខ្ញុំត្រូវការមេធាវី ខ្ញុំបានស្នើឈ្មោះគាត់រួចហើយ។ សម្រាប់មេធាវីបរទេស ខ្ញុំអត់ស្គាល់ឈ្មោះ នៅឡើយទេ។ ខ្ញុំស្គាល់តែលោក សុន អរុណ មេធាវីជាតិប៉ុណ្ណោះ។

Marcel Lemonde: ខ្ញុំចង់ពន្យល់លោកថាអ្នករាល់គ្នានៅទីនេះយល់ថាលោកអាចរង់ចាំបានពីព្រោះនោះគឺជាប្រយោជន៍របស់លោក លោកអាចរង់ចាំបានរហូតទាល់តែមេធាវីរបស់

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. E.T.C. ១៣

00172948

C1/1/54

លោកមក ដូចនេះ សវនាការតទល់គ្នាអាចធ្វើទៅបានពីព្រោះក្នុងសវនាការនោះ នឹងពិចារណាអំពីលទ្ធភាពនៃការឃុំខ្លួនបណ្ដោះអាសន្ន ប៉ុន្តែប្រសិនបើលោកអាចការពារខ្លួនឯងបានក្នុងនីតិវិធីនៅពេលនេះដោយគ្មានវត្តមានរបស់មេធាវី ដូច្នេះយើងអាចបន្តនីតិវិធីបាន។

នួន ជា: ខ្ញុំសូមបំភ្លឺថាខ្ញុំអាចការពាររឿងក្តីនេះដោយខ្លួនឯងបានក្នុងពេលឥឡូវនេះ ប៉ុន្តែចាប់ពីថ្ងៃស្អែកទៅ នៅពេលមេធាវីរបស់ខ្ញុំមក ខ្ញុំនឹងត្រូវការជំនួយពីគាត់។ សម្រាប់មេធាវីអន្តរជាតិ ខ្ញុំនឹងសុំយោបល់ពីមេធាវីជាតិរបស់ខ្ញុំ។

១៦. ផ្ទុយពីវិធាន៥៨(២)នៃវិធានផ្ទៃក្នុង វិធាន៦៣(១)នៃវិធានផ្ទៃក្នុង មិនបានចែងឲ្យបានច្បាស់អំពីលទ្ធភាពនៃការលះបង់សិទ្ធិទាក់ទងការសួរយកចម្លើយជនត្រូវចោទឡើយ។វិធាន ៥៨(២) មានចែងផ្នែកដែលពាក់ព័ន្ធថា:

> ការសួរចម្លើយជនត្រូវចោទត្រូវតែធ្វើឡើងដោយមានវត្តមានរបស់មេធាវី លើកលែងតែជនត្រូវចោទយល់ព្រមឆ្លើយដោយមិនចាំបាច់មានវត្តមានមេធាវីរបស់ខ្លួន និងត្រូវសរសេរចូលក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរមួយដោយឡែកដោយមានហត្ថលេខា ឬស្នាមម្រាមដៃរបស់ជនត្រូវចោទ ហើយត្រូវដាក់ចូលទៅក្នុងសំណុំរឿង។ ការយល់ព្រមឆ្លើយដោយមិនចាំបាច់មានវត្តមានមេធាវីរបស់ជនត្រូវចោទ ត្រូវថតទុកដូចមានចែងក្នុងវិធាន ២៥[10]។

១៧. អង្គបុរេជំនុំជម្រះយល់ឃើញថា វិធាន៥៨(២)នៃវិធានផ្ទៃក្នុង មិនអនុវត្តចំពោះសវនាការតទល់គ្នាស្តីពីការឃុំខ្លួនបណ្ដោះអាសន្ននោះទេ។ សវនាការតទល់គ្នា គឺមានគោលដៅខុសគ្នាពីការសួរចម្លើយជនត្រូវចោទ។ សវនាការតទល់គ្នាផ្តល់ឲ្យជនត្រូវចោទនូវឱកាសឆ្លើយតបទៅនឹងសំណើនិងអំណះអំណាងដែលលើកឡើងដោយសហព្រះរាជអាជ្ញា។ ការសួរចម្លើយគឺជាផ្នែកមួយនៃការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតដើម្បីស្វែងរកការពិត និងមានគោលដៅយកចម្លើយរបស់ជនត្រូវចោទ ជាចម្លើយដែលអាចប្រើជាភស្តុតាងប្រឆាំងនឹងជនត្រូវចោទបាន ។ ដោយមិនគិតអំពីនីតិវិធី ក្នុងខណៈដែលវិធាន៥៨ នៃវិធានផ្ទៃក្នុង អាចត្រូវបានបកស្រាយដើម្បីអនុវត្តចំពោះរាល់ការសួរចម្លើយជនត្រូវចោទ វិធាននេះមិនអនុវត្តបានទេក្នុងករណីនេះ ព្រោះថាជនត្រូវចោទមិនត្រូវបានសួរចម្លើយក្នុងកំឡុងពេលសវនាការ

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C *

[10] វិធានផ្ទៃក្នុង អ.វ.ត.ក , ០១ កុម្ភៈ ២០០៨ វិធាន ៥៨(២)

00172949

C11/54

តទល់គ្នាឡើយ[១១]។ ដូច្នេះលក្ខខណ្ឌតម្រូវក្នុងវិធាន៥៨នៃវិធានផ្ទៃក្នុងអំពីការលះបង់សិទ្ធិមានមេធាវីដែលត្រូវបានធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរដាច់ដោយឡែក និងដោយមានហត្ថលេខារបស់ជនត្រូវចោទ គឺមិនអនុវត្តចំពោះករណីនេះទេ។

១៨. អង្គបុរេជំនុំជម្រះយល់ឃើញថា លទ្ធភាពនៃការលះបង់សិទ្ធិមានមេធាវីក្នុងពេលសវនាការតទល់គ្នា អាចទាញការសន្និដ្ឋានពីវិធាន ៦៣(១)។ យោងតាមវិធាននេះ ជនត្រូវចោទដែលគ្មានមេធាវីនឹងត្រូវបានជូនដំណឹងអំពីសិទ្ធិមានមេធាវី ដូច្នេះជនត្រូវចោទអាចលះបង់សិទ្ធិនេះបាន។

១៩. អង្គជំនុំជម្រះសាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី (“ICTY”) និងតុលាការព្រហ្មទណ្ឌអន្តរជាតិនៅរ៉ូហ្វាន់ដា(“ICTR”) បានធ្វើការត្រួតពិនិត្យលើសុពលភាពនៃការលះបង់សិទ្ធិមានមេធាវី[១២]។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា តុលាការទាំងនេះបានអនុវត្តលក្ខខណ្ឌខុសៗគ្នា សម្រាប់ការលះបង់សិទ្ធិនេះនៅក្នុងដំណាក់កាលផ្សេងៗគ្នានៃកិច្ចដំណើរការនីតិវិធី។

២០. នៅក្នុងរឿងក្តី *Bagosora* អង្គជំនុំជម្រះសាលាដំបូងរបស់ ICTR បានចាត់ទុកថា ដើម្បីឱ្យមានប្រសិទ្ធិភាព ការលះបង់សិទ្ធិត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត និងច្បាស់លាស់[១៣]។ នៅក្នុងរឿងក្តីនេះ Bagosora ជាជនសង្ស័យ បានលះបង់សិទ្ធិមានមេធាវី នៅពេលដែលគាត់កំពុងត្រូវគេសួរចម្លើយ។

---

[១១] ជនត្រូវចោទ នួន ជា, កំណត់ហេតុជាលាយលក្ខអក្សរនៃសវនាការតទល់, ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០០៧ (សំណុំរឿង: 002/19-09-2007-ECCC/OCIJ, C8 )

[១២] សូមមើលករណី*រដ្ឋអាជ្ញា v. Krajisnik,* IT-00-39-T, “មូលហេតុចំពោះការសម្រេចផ្ទាល់មាត់បដិសេធសំណើរបស់លោក Krasisnik ដែលស្នើអោយបន្តការកាត់សេចក្តីដោយមិនមានវត្តមានរបស់មេធាវី”, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៥ (“*មូលហេតុរបស់ Krajisnik ចំពោះសំណើបដិសេធអោយបន្តសវនាការដោយមិនមានតំណាង*”)។ *ព្រះរាជអាជ្ញា v. Bagosora, ICTR-98-44-T,* “សេចក្តីសម្រេចស្តីពី សំណើរបស់ព្រះរាជអាជ្ញាដោយសុំដាក់បញ្ចូលនូវឯកសារមួយចំនួនក្រោមវិធាន ៨៩(គ)”, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៤ (“សេចក្តីសម្រេចរបស់ *Bagosora* ”)។

[១៣] សេចក្តីសម្រេចរបស់ *Bagosora* , វាក្យខណ្ឌ ១៧ និង ១៨

PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

00172950

CM/54

២១. ទាក់ទងទៅនឹងលក្ខខណ្ឌតម្រូវដែលថា ការលះបង់សិទ្ធិត្រូវតែធ្វើឡើងដោយច្បាស់លាស់នោះ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា "ការលះបង់សិទ្ធិត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់ និងហួសពីវិមតិសង្ស័យ"។ ការលះបង់សិទ្ធិត្រូវតែស្តែងចេញ និងធ្វើឡើងដោយច្បាស់លាស់ ហើយត្រូវតែទាក់ទងយ៉ាងច្បាស់ទៅនឹងការសម្ភាសន៍ ដែលក្នុងនោះមានការសួរយកចម្លើយដែលពាក់ព័ន្ធ [១៤]។

២២. អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា យោងតាមយុត្តាធិការជាតិ ការលះបង់សិទ្ធិអាចចាត់ទុកថាធ្វើឡើងដោយការស្ម័គ្រចិត្តបាន លុះត្រាតែអ្នកជាប់ឃុំយល់ដឹងពីសិទ្ធិដែលខ្លួនត្រូវទទួលបាន[15]។ អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញបន្ថែមទៀតថា "ដែលចាត់ទុកបានដឹងច្បាស់ ជនសង្ស័យត្រូវបានជូនដំណឹងអំពីសិទ្ធិ រួមទាំងសិទ្ធិមានមេធាវីទាន់ពេលវេលានៅមុនពេល និងកំឡុងពេលនៃការសួរយកចម្លើយនិមួយៗ។ ហេតុផលណាមួយដែលថាសិទ្ធិដែលត្រូវទទួលបានមានលក្ខខណ្ឌ ឬថា វត្តមានមេធាវីអាចត្រូវបានពន្យាររហូតដល់ការសួរយកចម្លើយត្រូវបានបញ្ចប់ដែលបណ្តាលឱ្យមានការលះបង់សិទ្ធិណាមួយនោះ នឹងគ្មានប្រសិទ្ធភាពទេ"[16]។

២៣. អង្គជំនុំជម្រះសាលាដំបូងរបស់ ICTY ត្រូវប្រឈមជាមួយស្ថានការណ៍ដែលមានលក្ខណៈខុសពីនេះនៅក្នុងរឿងក្តីរបស់ *Krajisnik* ។ នៅក្នុងរឿងក្តីនេះ ជនជាប់ចោទបានស្នើសុំឱ្យបន្តសវនាការរបស់ខ្លួន ដោយគ្មានវត្តមានមេធាវីការពារក្តី។ អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកថា "មុននឹងសំណើសុំ [បន្តសវនាការដោយគ្មានវត្តមានមេធាវីការពារក្តី] អាចនឹងត្រូវលើកយកមកពិចារណាក្រោមលក្ខខណ្ឌរបស់ខ្លួននោះ ទាំងក្នុងន័យច្បាប់ ទាំងន័យធម្មតាទូទៅ ទាមទារឱ្យមានការស៊ើបអង្កេតជាបឋមជាមុនសិន ដើម្បីកំណត់ថាតើសំណើដែលលើកឡើងនេះធ្វើឡើងដោយច្បាស់លាស់ ដោយមានការជូនដំណឹង និងដោយមានការ

---

[១៤] សេចក្តីសម្រេចរបស់ *Bagosora*, វាក្យខណ្ឌ ១៨

[15] សេចក្តីសម្រេចរបស់ *Bagosora*, footnote 12

[16] សេចក្តីសម្រេចរបស់ *Bagosora* កថាខ័ណ្ឌ ១៧

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ពិចារណាដែរឬទេ"[១៧]។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូងមិនបានភ្ជាប់ដោយជាក់លាក់នូវលក្ខខណ្ឌតម្រូវការទាំងនេះទៅនឹងការលះបង់សិទ្ធិមានមេធាវីក៏ដោយ អង្គបុរេជំនុំជម្រះសង្កេតឃើញថា យុត្តិសាស្ត្រសហរដ្ឋអាមេរិកដែលអង្គជំនុំជម្រះសាលាដំបូងបានលើកឡើងនោះ មានបង្ហាញពីការភ្ជាប់យ៉ាងជាក់លាក់នូវលក្ខខណ្ឌតម្រូវការទាំងនេះទៅនឹងការលះបង់សិទ្ធិក្នុងការមានមេធាវី[១៨]។ ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ការស៊ើបសួរ និងលក្ខខណ្ឌតម្រូវការដែលបានអនុវត្តដោយអង្គជំនុំជម្រះសាលាដំបូង មានការពាក់ព័ន្ធទៅនឹងការលះបង់សិទ្ធិមានមេធាវីការពារក្តី។ ប៉ុន្តែអង្គបុរេជំនុំជម្រះសង្កេតឃើញផងដែរថា "ការលះបង់សិទ្ធិ" របស់ Krajisnik បានធ្វើឡើងនៅក្នុងដំណាក់កាលជំនុំជម្រះអង្គសេចក្តី។

---

[១៧] មូលហេតុក្នុងរឿងក្តី *Krajisnik* , កថាខ័ណ្ឌទី ៥

[១៨] អង្គជំនុំជម្រះពន្យល់អំពីលក្ខខណ្ឌតម្រូវនានានៅក្នុងកំណត់ត្រារបស់ខ្លួន។ កំណត់ត្រាលេខ ៦ ពោលថា "ការស៊ើបសួរគឺមានពាក់ព័ន្ធនឹងយុត្តិសាស្ត្រដែលចង្អុលយោងទៅក្នុងផ្នែកទីពីរនៃសំអាងហេតុទាំងនេះ"។ នៅក្នុងផ្នែកទីពីរនេះ អង្គជំនុំជម្រះពិចារណាកថាខ័ណ្ឌទី ២៣ ថា "អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានបន្តសម្រេចថា ជនជាប់ចោទមានសិទ្ធិទទួលបានសិទ្ធិធ្វើជាតំណាងឲ្យខ្លួនឯងបាន។ [...] ដើម្បីឈានទៅសន្និដ្ឋានបែបនេះបាន អង្គជំនុំជម្រះសាលាឧទ្ធរណ៍ពឹងផ្អែកទាំងលើពាក្យពេចន៍នៃលក្ខន្តិកៈរបស់សាលាក្តី និងករណីរបស់សហរដ្ឋអាមេរិកក្នុងរឿងក្តី Faretta ទល់នឹង California។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានពឹងផ្អែកលើករណីនេះតាំងតែពីមានបណ្តឹងឧទ្ធរណ៍ពីដើមដំបូងមកម្ល៉េះ។ Faretta ត្រូវបានស្វាគមន៍ដោយអង្គជំនុំជម្រះសាលាដំបូងថាជា "សេចក្តីថ្លែងបែបប្រពៃណីមួយនៃសិទ្ធិក្នុងការធ្វើជាតំណាងដោយខ្លួនឯង" ហើយអង្គជំនុំជម្រះសាលាឧទ្ធរណ៍ក៏ឯកភាពដូចអញ្ចឹងផងដែរ"។ ក្នុងរឿងក្តី Faretta ទល់នឹង California (១៩៧៥) ៤២២ សហរដ្ឋអាមេរិក ៨០៦, តុលាការកំពូលរបស់សហរដ្ឋអាមេរិកសម្រេចដោយយោងទៅសាលដីការបស់ខ្លួន "ដោយមិនចាំបាច់ផលប្រយោជន៍ដែលគេបោះបង់ចោលទាំងនោះ"។ ក្នុងរឿងក្តី Johnston ទល់នឹង Zerbst, តុលាការបានពិចារណាត្រង់ចំណុច ៤៦៤-៤៦៥ ថា "វិសោធនកម្មទី៦ បានយកអំណាច និងសមត្ថកិច្ចមកវិញពីតុលាការសហព័ន្ធ ពីក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌទាំងអស់ នៃការដកហូតសិទ្ធិមានជីវិត ឬមានសេរីភាពពីជនជាប់ចោទ វៀរលែងតែគាត់មាន ឬលះបង់សិទ្ធិមានជំនួយពីមេធាវី។ [...] សិទ្ធិដែលអនុញ្ញាតដោយធម្មនុញ្ញដែលជនជាប់ចោទត្រូវមានមេធាវីការពារក្តីឲ្យនេះ គឺតម្រូវឲ្យសាលាដំបូងជួយការពារសិទ្ធិនេះ ព្រោះសិទ្ធិមានជីវិត ឬមានសេរីភាពរបស់ជនជាប់ចោទអាចនឹងត្រូវខូចបង់ ប្រសិនបើគ្មានមេធាវីជួយការពារក្តីឲ្យនោះទេ។ ភារកិច្ចក្នុងការការពារនេះ បានដាក់នូវទម្ងន់ និងការទទួលខុសត្រូវដ៏ធំធេងមួយសម្រាប់ចៅក្រមសាលាដំបូង ក្នុងការសម្រេចសេចក្តីថាតើជនជាប់ចោទ ពិតជាបានលះបង់សិទ្ធិរបស់គាត់នេះបានធ្វើឡើងដោយត្រឹមត្រូវ និងពេញលេញឬយ៉ាងណា"។

00172952

C11/54

២៤. ក្រោយមក អង្គជំនុំជម្រះសាលាដំបូងរបស់ ICTY យល់ឃើញថា "មន្ទិលសង្ស័យ" មានន័យថា "មិនច្បាស់លាស់ចំពោះអត្ថន័យ ឬចេតនា មិនប្រាកដប្រជា [...]។ សំណើដែលធ្វើឡើងដោយមានលក្ខខណ្ឌ ឬដោយជម្រើស អាចនឹងមិនមានភាពខ្វះចន្លោះនូវភាពប្រាកដប្រជា។ ប៉ុន្តែក្នុងករណីដែលតុលាការមិនមានជំនឿថា អ្នកដាក់សំណើពិតជាមានមានបំណងចង់ជ្រើសយកជម្រើសធ្វើជាតំណាងដោយខ្លួនឯងបាន[...] តុលាការមិនមានជម្រើសច្រើនទេ ក្រៅពីយល់ឃើញថា សំណើនោះមានភាពមិនច្បាស់លាស់ចំពោះអត្ថន័យ ឬ ចេតនា និងមានភាពមិនប្រាកដប្រជា ដូច្នេះហើយទើបយល់ថា មានមន្ទិលសង្ស័យ"[១៩]។

២៥. ទាក់ទងទៅនឹងលក្ខខណ្ឌតម្រូវដែលថា ការលះបង់សិទ្ធិត្រូវតែ "បានជូនដំណឹង" និង "បានពិចារណា"នោះ អង្គជំនុំជម្រះសាលាដំបូងបានកត់សំគាល់ថា វាគ្រាន់តែជាទស្សនៈដំបូងដែលយល់ឃើញថា លក្ខខណ្ឌតម្រូវទាំងនោះមិនត្រូវបានបំពេញឡើយ។ សំណើមិនត្រូវបានជូនដំណឹង "ជាពិសេសទាក់ទងនឹងផលលំបាកនៃការអនុវត្តជាក់ស្តែង និងផលលំបាកផ្នែកហិរញ្ញវត្ថុនៃសេចក្តីសម្រេចបែបនេះ" ហើយមិនបានពិចារណាគឺ "ក្នុងន័យដែលថាជនជាប់ចោទមិនបានផ្តល់ការវាយតម្លៃដោយសមហេតុផល ទៅលើបន្ទុកនៃការអនុវត្តរឿងក្តីឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ ពីការឃុំឃាំងនៃមណ្ឌលឃុំខ្លួនអង្គការសហប្រជាជាតិ និងទៅលើគ្រោះថ្នាក់ដែលអាចកើតមាន និងមិនទាន់ស្តែងចេញ ដែលបណ្តាលមកពីពីជម្រើសបែបនេះ"[២០]។

២៦. ទោះបីជាអង្គជំនុំជម្រះសាលាដំបូងរបស់ ICTY និង ICTR បានប្រើពាក្យពេចន៍ខុសគ្នាក៏ដោយ ក៏អង្គជំនុំជម្រះទាំងពីរនេះបានអនុវត្តនូវលក្ខខណ្ឌតម្រូវដូចគ្នាដែរ។ អង្គបុរេជំនុំជម្រះទាញសន្និដ្ឋានពីសេចក្តីសម្រេចនេះបានថា ដើម្បីឱ្យការលះបង់សិទ្ធិមួយមានសុពលភាព ការលះបង់នោះ គួរធ្វើឡើងដោយច្បាស់លាស់ និងដោយស្ម័គ្រចិត្ត។ ដែលចាត់ទុកថាស្ម័គ្រចិត្ត ការលះបង់សិទ្ធិគួរតែមានការជូនដំណឹង ឬបានយល់ដឹង និងបានពិចារណា។

[19] មូលហេតុក្នុងរឿងក្តី *Krajisnik*, កថាខណ្ឌទី ៦

[20] មូលហេតុក្នុងរឿងក្តី *Krajisnik*, កថាខណ្ឌទី ៨

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

២៧. អង្គបុរេជំនុំជម្រះយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងទាំងពីរ បានអនុវត្តតាមលក្ខខណ្ឌតម្រូវនៃការលះបង់សិទ្ធិដោយច្បាស់លាស់មួយតាមមធ្យោបាយដូចគ្នានេះដែរ ហើយក្នុងករណីនេះ យើងនឹងយកវាមកអនុវត្តតាមការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូងទាំងពីរ។

២៨ ចំពោះបញ្ហានៃលក្ខខណ្ឌតម្រូវនៃការស្ម័គ្រចិត្ត អង្គជំនុំជម្រះបានប្រើបទដ្ឋានផ្សេងពីនេះ។ ក្នុងពេលដែលរឿងក្តីរបស់ *Bagosora* ត្រូវបានតុលាការបានសម្រេចថាវាមានលក្ខណៈគ្រប់គ្រាន់ហើយក្នុងការជូនដំណឹងដល់ជនសង្ស័យអំពីសិទ្ធិមានមេធាវី ហើយក្នុងរឿងក្តីរបស់ *Krajišnik* បទដ្ឋានខ្ពស់ជាងនេះត្រូវបានអនុវត្ត ដោយតម្រូវឲ្យមានព័ត៌មានអំពីផលលំបាកនៃការអនុវត្តជាក់ស្តែង និងផលលំបាកផ្នែកហិរញ្ញវត្ថុនៃកិច្ចដំណើរការនីតិវិធីដោយគ្មានមេធាវីមុននឹងចេញសេចក្តីសម្រេចមួយប្រកបដោយគតិបណ្ឌិត។

២៩. ដូចបានជម្រាបជូនខាងលើរួចមកហើយ ទាក់ទងនឹងចំណុចនេះ ករណីលះបង់សិទ្ធិគឺស្ថិតក្នុងដំណាក់កាលខុសៗគ្នានៃកិច្ចដំណើរការនីតិវិធី។ ក្នុងរឿងក្តីរបស់ *Bagosora* ការលះបង់សិទ្ធិគឺពាក់ព័ន្ធនឹងការសួរយកចម្លើយជនសង្ស័យ។ ក្នុងរឿងក្តីរបស់ *Krajišnik* ការលះបង់សិទ្ធិគឺពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិក្នុងការធ្វើតំណាងដោយខ្លួនឯង។

៣០. អង្គបុរេជំនុំជម្រះយល់ឃើញថា ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីកំណត់នូវព័ត៌មាន ដែលត្រូវការចាំបាច់ដើម្បីបង្កើតឲ្យមាននូវការលះបង់សិទ្ធិដែលត្រូវបានជូនដំណឹង ។ ក្នុងករណីនៃការសួរយកចម្លើយ វាច្បាស់ណាស់ថា ការបន្តកិច្ចដំណើរការនីតិវិធីដោយគ្មានមេធាវីអាចបណ្តាលឲ្យមានការបង្កើតនូវភស្តុតាងដាក់បន្ទុកមិនសមស្រប។

៣១. ដើម្បីលះបង់សិទ្ធិមានមេធាវី*ដោយបានដឹង និងបានពិចារណាត្រឹមត្រូវនោះ* ជនត្រូវចោទត្រូវតែអាចមានលទ្ធភាពអាចយល់ដឹង បានដោយសមហេតុផលពីផលប៉ះពាល់នៃកិច្ចដំណើរការនីតិវិធី ដោយគ្មានមានមេធាវី។

PRE-TRIAL CHAMBER * E.C.C.C. * C.E.T.C. * CHAMBRE PRELIMINAIRE

00172954

C11/54

៣២. សវនាការតទល់គ្នាគឺជាសវនាការចាំបាច់ ដែលត្រូវធ្វើមុននឹងចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ។ សវនាការតទល់គ្នាផ្ដល់ឱកាសដល់ជនត្រូវចោទដើម្បីឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំឲ្យចេញដីកាបែបនេះ ។ បន្ទាប់ពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់គូភាគីរួចមក សហចៅក្រមស៊ើបអង្កេតអាចបង្គាប់ឲ្យឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្នបាន។

៣៣. ក្នុងពេលបង្ហាញខ្លួនជាលើកដំបូង និងក្នុងពេលសវនាការតទល់របស់ជនត្រូវចោទ សហចៅក្រមស៊ើបអង្កេតបានប្រាប់ជនត្រូវចោទម្ដងហើយម្ដងទៀត អំពីសិទ្ធិមានមេធាវីរបស់ជនត្រូវចោទ និងបានសួរជនត្រូវចោទទៀតតើខ្លួនត្រូវការឲ្យមានមេធាវីដែរឬទេ ។ សហចៅក្រមស៊ើបអង្កេតបានប្រាប់ជនត្រូវចោទបន្ថែមទៀតអំពីគោលបំណង និង នីតិវិធីក្នុងពេលធ្វើសវនាការតទល់គ្នា ដែលសវនការនេះធ្វើឡើងដើម្បីផលប្រយោជន៍របស់ជនត្រូវចោទ ក្នុងការបន្តនីតិវិធីដោយមានមេធាវី ។ ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ការលះបង់សិទ្ធិរបស់ជនត្រូវចោទ គឺបានធ្វើឡើងដោយមានការជូនដំណឹង។

៣៤. ទោះបីនៅក្នុងរឿងក្ដីនេះ បទចោទដែលជនត្រូវចោទប្រឈមមុខមានលក្ខណៈស្មុគស្មាញយ៉ាងណាក៏ដោយ ជនត្រូវចោទបានលះបង់សិទ្ធិមានមេធាវីក្នុងពេលសវនការតទល់គ្នានេះ។ នៅពេលនេះ ពុំមានព័ត៌មាននៅក្នុសំណុំរឿងឡើយ រួមទាំងការថតវីដេអូនៃសវនាការរបស់សហចៅក្រមស៊ើបអង្កេត ហើយសហមេធាវីពុំមានអ្វីបង្ហាញ ដែលនាំឲ្យមានការសន្និដ្ឋានថាជរាភាព ឬ*ស្ថានភាពសុខភាពរបស់ជនត្រូវចោទ*ជាឧបសគ្គក្នុងការធ្វើសេចក្ដីសម្រេចរបស់ខ្លួនឡើយ។

៣៥. ក្នុងសវនាការលើបណ្ដឹងឧទ្ធរណ៍ សហមេធាវីបានលើកឡើងថា ជនត្រូវចោទបានប្រាប់ទៅផ្នែកគាំពារការពារក្ដីមុនការបង្ហាញខ្លួនលើកដំបូងថា គាត់គ្មានភាពរឹងប៉ឹងដើម្បីអាចបន្តកិច្ចដំណើរការនីតិវិធីបានទេ ។ យោងតាមកំណត់ហេតុប្រជុំដែលមានការលុបចេញនូវព័ត៌មានមួយចំនួនរបស់ផ្នែកគាំពារការពារក្ដី ដែលសហមេធាវីបានដាក់ជូនមកបន្ទាប់ពីសវនាការលើបណ្ដឹងឧទ្ធរណ៍ ផ្នែកគាំពារការពារក្ដីបានប្រាប់ទៅជនត្រូវចោទថា គាត់អាចស្នើសុំសហចៅក្រមស៊ើបអង្កេតឲ្យពន្យារកិច្ចដំណើរការនីតិវិធីបាន ។ ក្រោយមក ជនត្រូវចោទ

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C.

សុំឱ្យផ្នែកគាំពារការពារក្ដីបញ្ចុះបញ្ចូលឱ្យសហចៅក្រមស៊ើបអង្កេត ទុកពេលឱ្យគាត់បានសម្រាកផង ។ កំណត់ហេតុប្រជុំបង្ហាញឱ្យដឹងថា ផ្នែកគាំពារការពារក្ដីបានប្រាប់អំពីសំណើនេះបន្តទៅការិយាល័យសហចៅក្រមស៊ើបអង្កេតតាមទូរស័ព្ទ។

៣៦. អង្គបុរេជំនុំជម្រះសង្កេតឃើញថា កិច្ចប្រជុំរបស់ផ្នែកគាំពារការពារក្ដីបញ្ចប់ម៉ោង ១:០០ រសៀល និងការបង្ហាញខ្លួនលើកដំបូងចាប់ផ្ដើមម៉ោង ២ និង៤០នាទី រសៀល។ បើតាមខ្សែអាត់វីដេអូដែលបានថតសវនាការទាំងនេះ ជនត្រូវចោទមិនបានសុំសហចៅក្រមស៊ើបអង្កេតឱ្យលើកពេលឡើយបើទោះជាគេផ្ដល់លទ្ធភាពជូនគាត់ ក្នុងការសុំពន្យាពេលសវនាការតទល់គ្នានេះក៏ដោយ ។ ជនត្រូវចោទមិនបានប្រើប្រាស់ឱកាសដើម្បីសុំលើកពេលសវនាការនេះទេ ។ ម្យ៉ាងវិញទៀត ជនត្រូវចោទពុំបានជម្រាបជូនសហចៅក្រមស៊ើបអង្កេតអំពីបញ្ហាសុខភាពរបស់ខ្លួនទេ ហើយសហចៅក្រមស៊ើបអង្កេតក៏ពុំបានលើកឡើងអំពីបញ្ហានេះដែរ។ ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ពុំមានភស្ដុតាងបញ្ជាក់ថា ជនត្រូវចោទពុំមានលទ្ធភាពធ្វើការលះបង់សិទ្ធិដោយសុពលភាពដោយសារស្ថានភាពផ្លូវកាយរបស់ខ្លួនឡើយ។

៣៧. អង្គបុរេជំនុំជម្រះពិចារណាឃើញថា ជនត្រូវចោទដែលមានការអប់រំ និងកាលពីអតីតកាលធ្លាប់កាន់តួនាទីនយោបាយខ្ពស់មួយ និងដោយគាត់ត្រូវបានពន្យល់ប្រាប់ពីព័ត៌មានដូចបានពោលខាងលើ រួមទាំងក្នុងបរិបទនៃសវនាការតទល់គ្នានេះ គឺគាត់ពិតជាអាចធ្វើការស្វែងយល់បានត្រឹមត្រូវអំពីផលលំបាកនៃនីតិវិធីដែលគ្មានមេធាវីចូលរួម ។

៣៨. ជនត្រូវចោទបានបញ្ជាក់ម្ដងហើយម្ដងទៀតថា គាត់អាចបន្តកិច្ចដំណើរការនីតិវិធីមួយចំនួនទាំងនោះបានដោយមិនចាំបាច់មានមេធាវី ប៉ុន្តែក្នុងកិច្ចដំណើរការនីតិវិធីក្រោយៗទៀត គាត់ចាំបាច់ត្រូវមានមេធាវីរបស់គាត់ធ្វើតំណាងឱ្យគាត់ ។ អង្គបុរេជំនុំជម្រះ យល់ឃើញថាការបញ្ជាក់បែបនេះ បង្ហាញថាជនត្រូវចោទចង់លះបង់សិទ្ធិមានមេធាវីរបស់គាត់ ហើយការសម្រេចចិត្តរបស់គាត់គឺធ្វើឡើងដោយច្បាស់លាស់។

៣៩. ចុងក្រោយ បន្ទាប់ពីពិចារណាលើលក្ខខណ្ឌតម្រូវនៃការលះបង់សិទ្ធិ និងកាលៈទេសៈនានានៃករណីនេះ អង្គបុរេជំនុំជម្រះរកឃើញថា ការលះបង់សិទ្ធិរបស់ជនត្រូវចោទគឺធ្វើឡើងដោយច្បាស់លាស់ និងដោយស្ម័គ្រចិត្ត និងចាត់ទុកជាបានការ។

E.C.C.C. * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

៤០. នៅក្នុងបរិបទនៃសវនាការតទល់គ្នា សហមេធាវីការពារក្តីអះអាងផងដែរថា សិទ្ធិបន្ថែមរបស់ជនត្រូវចោទត្រូវបានរំលោភបំពាន ជាពិសេស សិទ្ធិទទួលបានសវនាការតទល់គ្នា សិទ្ធិទទួលបានពេលវេលាសមស្របដើម្បីត្រៀមការពារខ្លួន សិទ្ធិនៅស្ងៀមមិននិយាយស្តី និងសិទ្ធិទទួលបានសមភាពរវាងអយ្យការនិងមេធាវីការពារក្តី ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ក្នុងកំឡុងពេលនៃសវនាការតទល់ មិនមានការតាំងសំណួរចំពោះជនត្រូវចោទឡើយ ប៉ុន្តែផ្តល់ឱកាសឱ្យជនត្រូវចោទធ្វើការឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ដែលនេះគឺជាឱកាសដែលជនត្រូវចោទទទួលបាន ។ វាមិនមានការចោទជាសំណួរហើយនេះក៏មិនមែនជាគោលបំណងនៃសវនាកានេះឡើយ ។ ដូច្នេះ ការលើកឡើងអំពីសិទ្ធិនៅស្ងៀមមិននិយាយស្តីរបស់ជនត្រូវចោទមិនមានលក្ខណៈចាំបាច់ទេ ។ បន្ថែមលើចំណុចនេះ ជនត្រូវចោទត្រូវបានផ្តល់ឱកាសឲ្យអានឯកសារទាំងឡាយ ដែលសហព្រះរាជអាជ្ញាបានដាក់ជូនដើម្បីជាទឡ្ហីករណ៍លើសំណើរបស់ខ្លួន ប៉ុន្តែជនត្រូវចោទមិនបានប្រើប្រាស់ឱកាសនេះទេ ។ មិនត្រឹមតែប៉ុណ្ណោះ ជនត្រូវចោទយល់ឃើញថា មិនមានភាពចាំបាច់ក្នុងការពន្យាពេលសវនាការតទល់គ្នាទេ ក្នុងខណៈដែលការពន្យាពេលនេះត្រូវបានគេផ្តល់ជូនគាត់ តែជនត្រូវចោទបែរជាបង្ហាញអំពីបំណងយ៉ាងច្បាស់ថាខ្លួនចង់បន្តសវនាការ ។ ដូច្នេះអង្គបុរេជំនុំជម្រះ យល់ឃើញថា គ្មានសិទ្ធិបន្ថែមណាមួយរបស់ជនត្រូវចោទត្រូវបានរំលោភបំពានឡើយ។

## ជំពូក ៥ - ការពិនិត្យលើការបំពេញលក្ខខណ្ឌ អនុលោមតាមវិធាន៦៣(៣)នៃវិធានផ្ទៃក្នុង

៤១. វិធាន៦៣(៣)នៃវិធានផ្ទៃក្នុង ចែងថាៈ

សហចៅក្រមស៊ើបអង្កេត អាចចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ បានតែក្នុងលក្ខខណ្ឌដូចខាងក្រោមៈ

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C *

C11/54

ក. មានមូលហេតុដែលត្រូវបានរកឃើញនិងជឿជាក់ច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តិបទល្មើស មួយឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើប សួរបន្ថែម។

ខ. សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការឃុំខ្លួនបណ្ដោះអាសន្ន គឺជាវិធានការដ៏ចាំបាច់ដើម្បី:

(១) រារាំងកុំឱ្យជនត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឱ្យមានការ ត្រូវរូវគ្នារវាងជនត្រូវចោទ និង អ្នកសមគំនិតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការ របស់អង្គជំនុំជម្រះវិសាមញ្ញ។

(២) ថែរក្សាភស្តុតាង ឬ ការពារមិនឱ្យបំផ្លាញភស្តុតាង។

(៣) ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី។

(៤) ការពារសន្តិសុខឱ្យជនត្រូវចោទ ឬ

(៥) រក្សាសណ្ដាប់ធ្នាប់សាធារណៈ។

៤២. ដើម្បីធ្វើការសម្រេចថាតើ លក្ខខណ្ឌឃុំខ្លួនបណ្ដោះអាសន្ន ដូចមានចែងនៅក្នុងវិធាន៦៣(៣) បានបំពេញដែរឬទេ អង្គបុរេជំនុំជម្រះបានធ្វើការពិចារណាលើសេចក្ដីសន្និដ្ឋានលាយលក្ខណ៍ អក្សរ និង ផ្ទាល់មាត់របស់ភាគី និងភស្តុតាងដែលភាគីបានដាក់ជូនមកតាមរយៈសិទ្ធិ និងតាម រយៈការអនុញ្ញាត និងសំណុំរឿងទាំងមូលរបស់សហចៅក្រមស៊ើបអង្កេតរហូតដល់ថ្ងៃ សវនាការ។

ក. <u>មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់ច្បាស់ថា ជនត្រូវចោទ នួន ជា ធ្លាប់បានប្រព្រឹត្តិបទល្មើសមួយ ឬ ច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម (វិធាន៦៣(៣)(ក)នៃវិធានផ្ទៃក្នុង)</u>

៤៣. អង្គបុរេជំនុំជម្រះសង្កេតឃើញថា វិធានផ្ទៃក្នុងមិនបានចែងពន្យល់ថា កត្តាអ្វីខ្លះដែលចាត់ទុក ជាមូលហេតុដែលត្រូវបានរកឃើញ ។ ក្នុងន័យនេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា វិធានផ្ទៃក្នុងជាភាសាបារាំងប្រើពាក្យ “raison plausibles--មូលហេតុដែលត្រូវបានរក ឃើញ”ជំនួសពាក្យ “well founded reason--មូលហេតុដែលត្រូវបានរកឃើញ” គឺជា

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. * C.E.T.C.

ពាក្យដែលត្រូវគ្នានឹងពាក្យប្រើប្រាស់នៅក្នុងមាត្រា៥ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស។ មាត្រានេះចែង ដូចខាងក្រោម:

មនុស្សគ្រប់រូបមានសិទ្ធិទទួលបានសេរីភាព និងនិរន្តរាយ។ គ្មាននរណាម្នាក់អាចត្រូវបានគេ បំបាត់សេរីភាពរបស់ខ្លួននោះទេ លើកលែងតែក្នុងករណីដូចខាងក្រោម និងតាមមធ្យោបាយស្របច្បាប់:
គ) ប្រសិនបើគេត្រូវគេចាប់ខ្លួន និងឃុំខ្លួន ដើម្បីនាំខ្លួនចូលទៅចំពោះមុខអំណាចតុលាការ ដែលមានសមត្ថកិច្ច នៅពេលដែលមានមូលហេតុដែលត្រូវបានរកឃើញដោយសង្ស័យថាបានប្រព្រឹត្តបទល្មើសមួយ ឬថាមានមូលហេតុសមហេតុផលធ្វើឱ្យជឿថាមានភាពចាំបាច់ដើម្បីឃាត់ខ្លួន មិនឱ្យប្រព្រឹត្តបទល្មើសមួយ ឬមិនឱ្យរត់គេចខ្លួន បន្ទាប់ពីបានប្រព្រឹត្តបទល្មើសនេះរួច។

៤៤. តុលាការសិទ្ធិមនុស្សអឺរ៉ុប (“ECHR”) បានសម្រេចស្របគ្នាថា:

« [...] អត្ថិភាពនៃសេចក្តីសង្ស័យដែលល្មមគួរឱ្យជឿបាន ដោយសន្មតជាមុននូវអត្ថិភាពនៃហេតុការណ៍ ឬការណ៍សម្រាប់បញ្ចុះបញ្ចូលអ្នកសង្កេតដែលមិនលំអៀងម្នាក់ថា ជនដែលជាប់ក្នុងរឿងហេតុអាចបានប្រព្រឹត្តបទល្មើសនោះ។ ប៉ុន្តែ អ្វីដែលគេអាចចាត់ទុកថា « ត្រូវបានរកឃើញ » គឺស្រេចនៅលើកាលៈទេសៈទាំងអស់ »។[២១]

៤៥. នៅក្នុងសេចក្តីសម្រេចថ្មីៗរបស់អង្គបុរេជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (“ICC”) ក្នុងរឿងក្តី Ahmad Muhammad Harun (“Ahmad Harun”) និង Ali Muhammad Ali Abd-Al-Rahman (“Ali Kushayb”) អង្គជំនុំជម្រះបានពិចារណាឃើញថា តម្រូវឱ្យមានការបកស្រាយលើលក្ខន្តិកៈនៃបញ្ញត្តិដែលចែងអំពី“មូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់ច្បាស់លាស់” ដោយធ្វើយ៉ាងណាឱ្យស្របទៅនឹង សិទ្ធិមនុស្សដែលទទួលស្គាល់ជាអន្តរជាតិ។ អង្គជំនុំជម្រះធ្វើការសម្រេចថា:

“ហេតុដូច្នេះ ក្នុងការបកស្រាយ និងក្នុងការអនុវត្តបញ្ញត្តិដែលចែងអំពី “មូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់ច្បាស់លាស់” អង្គជំនុំជម្រះ នឹងអនុវត្តតាមបទដ្ឋានណែនាំស្តីពី “ការសង្ស័យ

---

[២១] តុលាការសិទ្ធិមនុស្ស រឿងក្តី Fox, Campbell និង Hartley តទល់នឹង ចក្រភពអង់គ្លេស, ថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៩០, កថាខណ្ឌទី ៣២។

00172959

C11154

ដែលសមហេតុផល” ដែលមានចែងក្នុងមាត្រា៥(១)(គ) នៃអនុសញ្ញាអ៊ឺរ៉ុបស្តីពីសិទ្ធិមនុស្ស និង យុត្តិសាស្ត្រនៃតុលាការអន្តរ-អាមេរិកកាំងស្តីពីសិទ្ធិមនុស្ស ស្តីពីសិទ្ធិសេរីភាពជាមូលដ្ឋានរបស់បុគ្គល ដូចមានចែងក្នុងមាត្រា៧ នៃអនុសញ្ញាអាមេរិកកាំងស្តីពីសិទ្ធិមនុស្ស”។[២២]

៤៦. ដូចតុលាការព្រហ្មទណ្ឌអន្តរជាតិធ្លាប់បានអនុវត្ត អង្គបុរេជំនុំជម្រះនឹងធ្វើការបកស្រាយពាក្យថា “មូលហេតុដែលត្រូវបានរកឃើញ” ដោយធ្វើការស្វែងរកបទដ្ឋានណែនាំ នៅក្នុងយុត្តិសាស្ត្ររបស់តុលាការអ៊ឺរ៉ុបស្តីពីសិទ្ធិមនុស្ស ។ នេះមានន័យថា អង្គបុរេជំនុំជម្រះត្រូវតែធ្វើការវិនិច្ឆ័យថា តើមានអង្គហេតុ ឬព័ត៌មាន ដែលនឹងធ្វើឱ្យអ្នកសង្កេតការដោយមិនលំអៀងជឿថា បុគ្គលដែលពាក់ព័ន្ធធ្លាប់បានប្រព្រឹត្តិបទល្មើសមែនដែរឬទេ។

៤៧. វិធាន៦៣(៣)(ក)នៃវិធានផ្ទៃក្នុង តម្រូវឱ្យមានលក្ខខណ្ឌបន្ថែមថា មូលហេតុដែលត្រូវបានរកឃើញនេះត្រូវពាក់ព័ន្ធជាមួយនឹង ការជឿជាក់ច្បាស់លាស់ថា ជនត្រូវចោទ “ធ្លាប់បានប្រព្រឹត្តិបទល្មើសមួយឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ”។ អនុលោមតាមមាត្រា២៩នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលប្រកាសឱ្យប្រើនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ពាក្យថា “បានប្រព្រឹត្តិ” រួមបញ្ចូលការរៀបចំផែនការណ៍ ការញុះញង់ ការបញ្ជា ការជួយនិងជម្រុញ ឬការប្រព្រឹត្តិ និងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ថ្នាក់លើ។

៤៨. ដើម្បីធានាឱ្យបានថា នឹងមិនមានការប៉ះពាល់ដល់ការស៊ើបអង្កេត អង្គបុរេជំនុំជម្រះធ្វើការកត់សម្គាល់ថា នៅក្នុងសាលដីកាជាសធារណៈ នឹងមិនមានសរសេរអំពីភស្តុតាងដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មជាក់លាក់ដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬក៏មិនមានភស្តុតាងពាក់ព័ន្ធនឹងធាតុផ្សំនៃឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ ។ បន្ទាប់ពីបានពិនិត្យលើសំណុំរឿង អង្គបុរេជំនុំជម្រះជឿថា មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់

---

[២២] រដ្ឋអាជ្ញា តទល់នឹង Ahmad Muhammad Harun (“Ahmad Harun”) និង Ali Muhammad Ali abd-Al-Rahman (“Ali Kushayb”) ICC-0២/0៥-0១/0៧ “សេចក្តីសម្រេចលើពាក្យសុំរបស់រដ្ឋអាជ្ញា អនុលោមតាមមាត្រា ៥៨(៧) នៃលក្ខន្តិកៈ” អង្គបុរេជំនុំជម្រះ ថ្ងៃទី២៧ ខែមេសា ឆ្នាំ ២00៧ កថាខណ្ឌ២៨។

CMS4

ច្បាស់លាស់ថា បទល្មើសជាក់លាក់ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ អាចត្រូវបានប្រព្រឹត្តិឡើងនៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធអន្តរជាតិ និង/ ឬ ជាផ្នែកនៃការវាយប្រហារលក្ខណៈជាប្រព័ន្ធនិងទ្រង់ទ្រាយធំដោយផ្អែកលើមូលហេតុនៃការរើសអើង ។ សហមេធាវី មិនបានតវ៉ាចំពោះអង្គហេតុដែលត្រូវចោទប្រកាន់ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទេ តែបានធ្វើការតវ៉ាអំពីការចូលរួមរបស់ជនត្រូវចោទទៅក្នុងបញ្ហាទាំងនោះ ។

៤៩. ពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវរបស់ជនត្រូវចោទ ចំពោះបទល្មើសជាក់លាក់ដែល ត្រូវបានចោទប្រកាន់មានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នៅក្នុងចំណោមឯកសារដទៃទៀត សំណុំរឿងមានចម្លើយជាច្រើនរបស់ជនត្រូវចោទ កាំង ហ្កេកអ៊ាវ ។ នៅក្នុងកិច្ចសម្ភាសន៍របស់ កាំង ហ្កេកអ៊ាវ ជាមួយតំណាងឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (UNHCR) គាត់បាននិយាយថា:

"សុន សេន បានបញ្ជូនរបាយការណ៍របស់ ស-២១ តាមរយៈ នួន ជា ទៅកាន់ជនបទ។ ចំណុចទី២ មានរូបលោក នួន ជា ដែលជាអគ្គលេខាធិការរងទីមួយ របស់បក្សកម្មុយនីស្តកម្ពុជា។ គាត់ ជាបុគ្គលដែលធ្វើការសម្រេចលើការងារទាំងឡាយ ហើយជាពិសេស នៅក្នុងការងារសន្តិសុខ គាត់មានតួនាទីសម្របសម្រួលរវាង ស-២១ និងភូមិភាគនីមួយៗ។ ដូច្នេះ ពាក់ព័ន្ធនឹងការងារសន្តិសុខ និង ការងារផ្ទៃក្នុងរបស់បក្ស នួន ជា គឺមានឋានៈលើ សុន សេន ទោះបី សុន សេន ជាបុគ្គលដែលធ្វើការសម្រេច និងដឹកនាំការងារមួយចំនួន ដោយផ្ទាល់ក៏ដោយ។"[២៣]

"សំនួរទី៥: ការបែងចែករវាង នួន ជា និង សុន សេន នៅក្នុងករណីស-២១។ ដូចដែលខ្ញុំបានបញ្ជាក់យ៉ាងច្បាស់ហើយថា នួន ជា គឺជាបុគ្គលសំខាន់។ សុន សេន គឺជាបុគ្គលថ្នាក់ក្រោមរបស់គាត់ ដែលដោះស្រាយលើបញ្ហាសន្តិសុខទូទាំងប្រទេស និង មិនត្រឹមតែក្នុង ស-២១ ប៉ុណ្ណោះទេ។ [ការសែតស្តាប់មិនឮ] នៅក្នុងករណីទីមួយ គឺលោក ប៉ុល ពត បានបញ្ចេញទស្សនៈលើការកែប្រែ វិធីធ្វើការរបស់ នួន ជា និង សុន សេន។ ករណីទី២ គឺករណីចាប់ខ្លួន ឈូក (Chhouk) ប្រធានកម្មាភិបាល

[២៣] ឯកសារបកប្រែជាភាសាអង់គ្លេសនៅក្នុងកិច្ចសម្ភាសន៍របស់ UNHCR ជាមួយ កាំង ហ្កេកអ៊ាវ ថ្ងៃទី៤-៦ ខែឧសភា ឆ្នាំ១៩៩៩ ដែលលោក Steve H. Heder បានធ្វើការចងក្រង នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ១៩៩៩ (ERN: 00002454-00002457)("កិច្ចសម្ភាសន៍របស់ UNHCR ជាមួយ កាំង ហ្កេកអ៊ាវ) ទំព័រ ១។

នៅតំបន់ ២៤។ នួន ជា និង សុន សេន បានធ្វើការរាយការណ៍បញ្ហានេះ ទៅ ប៉ុល ពត។ ខ្ញុំមិនដឹងថាតើមានចំនួនប៉ុន្មានដងទេ ដែលឱ្យ ប៉ុល ពត ដោះស្រាយបញ្ហា ឈូក នេះ... ហើយនឹងឱ្យធ្វើការកោះប្រជុំធ្វើការសម្រេចលើបញ្ហានេះ។ ខ្ញុំដឹងច្បាស់ណាស់អំពីបញ្ហានេះ នៅពេល សុន សេន បានបញ្ជាខ្ញុំឱ្យប្រមូលចងក្រងឯកសារ។ ខ្ញុំដឹងច្បាស់ណាស់ ពីព្រោះ សុន សេន ឱ្យខ្ញុំធ្វើការរៀបចំឯកសារ និងចម្លើយរបស់ខ្មាំង[...] បន្ទាប់ពីកិច្ចប្រជុំ សុន សេន ប្រាប់ខ្ញុំថា សោ ភឹម [Sao Pheum] មានការពេញចិត្ត ពីព្រោះគាត់ជឿថា ឈូក គឺជាខ្មាំង។ [...] ដូច្នេះ ដើម្បីធ្វើយ៉ាងណាឱ្យ សោ ភឹម សប្បាយចិត្ត ប្រហែល នួន ជា មិនសប្បាយចិត្ត... ចំពោះការចាប់ខ្លួន។ ដូច្នេះ គាត់ធ្វើអន្តរាគមជាមួយ ប៉ុល ពត ដើម្បីឱ្យគាត់ អាចធ្វើឱ្យ សោ ភឹម ជឿជាក់"។[២៤]

"នៅក្នុងប៉ុន្មានខែមុន នៅក្នុងចុងឆ្នាំ១៩៧៨។ ខ្ញុំមិនចងចាំថាមានចំនួនប៉ុន្មានរយនាក់ទេ ប៉ុន្តែអ្នកទាំងអស់នោះភាគច្រើនជាយុទ្ធជនពីកងកម្លាំងភូមិភាគបូព៌ា ហើយ នួន ជា បាននិយាយថា [មានចំនួនច្រើនណាស់] ដូច្នេះ មិនចាំបាច់ធ្វើការសួរចម្លើយទេ កំទេចពួកគេតែម្តងទៅ"[...] បញ្ហាបែបនេះមិនដែលធ្លាប់បានទទួលទេតាំងពីមុនមក ហើយយើងក៏មិនដែលធ្វើការរបៀបនេះដែរកាលពីមុនមក [...] ពួក គេជាជនស៊ីវិលផង និងជាទាហានផង"។[២៥]

"ខ្ញុំត្រូវបានដាក់ឱ្យបំពេញការងារថតរូបបុគ្គលមួយចំនួន បន្ទាប់ពីពួកគេត្រូវបានសម្លាប់។ [...] [សម្តេងបារាំង:] បញ្ហានេះ គឺចេញមកពី នួន ជា? [ឌុច:] ចេញពី នួន ជា មែន"។[២៦]

៥០. នៅក្នុងកិច្ចសម្ភាសជាមួយ Nate Thayer តាមរបាយការណ៍ កាំង ហ្កេកអ៊ាវ បាននិយាយថា

"បន្ទាប់ពីថ្ងៃរំដោះក្នុងឆ្នាំ ១៩៧៥ ប៉ុល ពត បាននិយាយថា: 'យើងត្រូវតែការពារបក្ស និងប្រទេសរបស់យើង ដោយត្រូវស្វែងរកខ្មាំងនៅក្នុងបក្សរបស់យើង។ យើងមិនមានសភាពរឹងមាំអាចតតាំងជាមួយខ្មាំងពីខាងក្រៅបានឡើយ។ ដូច្នេះ យើងធ្វើការសម្លាប់ខ្មាំងស៊ីរូងផ្ទៃក្នុង'។ ដំបូង យើងធ្វើការចាប់ខ្លួនពួកឧត្តរ បន្ទាប់មកពួកនិរតី បន្ទាប់មកពួកពាយ័ព្យ និង បន្ទាប់មកពួកបូព៌ា។ គាត់ប្រើ

[២៤] កិច្ចសម្ភាសន៍របស់ UNHCR ជាមួយ កាំង ហ្កេកអ៊ាវ ទំព័រ ៣,៤។
[២៥] កិច្ចសម្ភាសន៍របស់ UNHCR ជាមួយ កាំង ហ្កេកអ៊ាវ ទំព័រ ៩ និង ១០។
[២៦] កិច្ចសម្ភាសន៍របស់ UNHCR ជាមួយ កាំង ហ្កេកអ៊ាវ ទំព័រ ១១។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

C11/54

ប្រាស់ នួន ជា ឱ្យធ្វើការងារនេះ។ ប៉ុល ពត មិនបញ្ជាការសម្លាប់ដោយផ្ទាល់ទេ។ ជានិច្ចជាកាល នួន ជា នេះឃោឃៅហើយវាយឫក។ គាត់មិនដែលពន្យល់កម្មាភិបាលទេ។ គាត់គ្រាន់តែបញ្ជាប៉ុណ្ណោះ។"

"វ៉ន វេត(Vorn Vet) និង ចាយ គឹមហួរ (Chay Kim Hour) ត្រូវបាន នួន ជា បញ្ជាឱ្យសម្លាប់"។

"នួន ជា បញ្ជាខ្ញុំឱ្យដុតខ្មោចពួកគេ ដោយប្រើប្រាស់កង់ឡាន ដើម្បីកុំឱ្យនៅសល់ឆ្អឹង"។

"សេចក្តីសម្រេចឱ្យសម្លាប់ មិនមែនចេញពីបុគ្គលមួយរូបទេ គឺមិនមែន ប៉ុល ពត តែម្នាក់ឯងទេ ប៉ុន្តែ ជាសេចក្តីសម្រេចរបស់មជ្ឈិមបក្ស។ នួន ជា គឺជាមនុស្សសំខាន់ជាងគេ ចំពោះការកាប់សម្លាប់។ ប៉ុល ពត ចាប់អារម្មណ៍រឿង យុទ្ធសាស្ត្រយោធា។

ប៉ុល ពត ចាប់អារម្មណ៍លើយុទ្ធសាស្ត្រយោធា។ ចំណែកឯ ខៀវ សំផនមិនមានសិទ្ធិសម្រេចថាតើត្រូវ អ្នកណាខ្លះត្រូវចាប់ខ្លួន ហើយគាត់ក៏មិនមានសិទ្ធិបញ្ជាឱ្យយកអ្នកណាទៅសម្លាប់ ដែរ"។

"ប៉ុល ពត បានដឹងពីមន្ទីរស២១ ប៉ុន្តែគាត់មិនដឹកនាំមន្ទីរនេះផ្ទាល់ខ្លួនឡើយ។ គាត់ទុកការងារ នេះឱ្យ នួន ជា ដែលជាបងធំទីពីរក្នុងជួរបក្ស និងសុន សេន ដែលជាមេបញ្ជាការយោធា និងនគរបាល"។

"នួន ជា បានបញ្ជាឱ្យចាប់ខ្លួនទាហាន "ខ្មែរក្រហម" ចំនួន៣០០នាក់។ គាត់បានហៅខ្ញុំមកជួប ហើយសួរថា 'មិនចាំបាច់ខ្វល់សួរនាំពួកវាច្រើនទេ - សម្លាប់ពួកវាទាំងអស់ចោលទៅ" ហើយ ខ្ញុំក៏ធ្វើតាមបញ្ជា"។
"នួន ជា បានហៅខ្ញុំទៅការិយាល័យរបស់គាត់ ហើយគាត់បានបញ្ជាឱ្យខ្ញុំសម្លាប់អ្នកទោស ដែលនៅ សល់ទាំងអស់"[២៧]។

៥១. ក្នុងកិច្ចសួរយកចម្លើយរបស់សហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០០៧ កាំង ហ្កេកអ៊ាវ បាននិយាយថា៖

---

[២៧] លោក Nate Thayer ក្នុងព្រឹត្តិប័ត្រសេដ្ឋកិច្ចចុងបូព៌ា ចំណងជើង "មរណភាពក្នុងភាពពិស្ដារ" (ERN: 00087513 é 00087514)

* អង្គជំនុំជម្រះសាលាដំបូង * PRETRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

“ដំបូង ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូនពីជនរងគ្រោះដែលជាប់ឃុំនៅមន្ទីរស២១។ នៅថ្ងៃទី២ និងទី៣ នៃខែមករា ឆ្នាំ១៩៧៩ (ខ្ញុំមិនចាំច្បាស់) នួនជាបានហៅខ្ញុំឱ្យមកជួបដើម្បីទទួលបញ្ហាដាច់ខាតមួយ។ បញ្ហានោះគឺថា គាត់តម្រូវឱ្យមន្ទីរស២១កម្ទេច(សម្លាប់)ជនរងគ្រោះទាំងនោះចោលទាំងអស់។ ពាក់ព័ន្ធបញ្ហានេះ ខ្ញុំភ័យខ្លាចខ្លាំងណាស់។ ខ្ញុំបានសម្រេចចិត្តប្រាប់សមមិត្ត ហ៊័រ អំពីបញ្ហានេះ”[២៨]។

“សំណួររបស់ចៅក្រម យូ ប៊ុនឡេង: ទាក់ទងនឹងបញ្ហារបស់ នួន ជា នៅថ្ងៃទី២ និងទី៣ ខែមករា ឆ្នាំ១៩៧៩ តើមានជនរងគ្រោះប៉ុន្មាននាក់ត្រូវបានគេឃុំ ហើយតើគេកម្ទេចជនរងគ្រោះទាំងនោះយ៉ាងដូចម្តេច?

ចម្លើយ: ខ្ញុំមិនចាំចំនួនជនរងគ្រោះពិតប្រាកដទេ។ និយាយឱ្យចំទៅ ខ្ញុំមិនបានចាប់អារម្មណ៍លើចំណុចនេះកាលពីពេលនោះ។ ខ្ញុំនៅចាំបានថា កាលណោះមានជនរងគ្រោះពីរប្រភេទ៖ ទីមួយ ប្រជាជនកម្ពុជា និងទីពីរ ទាហានវៀតណាមដែលបានលើកដៃចុះចូលនៅឯសមរភូមិមុខ។

សំណួររបស់ចៅក្រមឡឺម៉ុងដ៏: តើពួកគេសុទ្ធតែជាឈ្លើយសឹកសង្គ្រាមមែនទេ?

ចម្លើយ: ពិតហើយ។

[......] សរុបប្រហែល២០០នាក់។ [.....] ខ្ញុំជឿថាពួកគេត្រូវបានសម្លាប់ចោលទាំងអស់”[២៩]។

“បន្ទាប់ពី នួន ជា បានឯកភាពលើសំណើរបស់ខ្ញុំសុំចាត់តាំង ហ៊័រ ប្រហែលពីរ ឬបីខែក្រោយមក នួន ជា បានប្រាប់ខ្ញុំថា ប្រធានមន្ទីរស២១មិនមែនខ្ញុំ ឌុចនោះទេ ប៉ុន្តែគឺរូបគាត់ នួន ជា ដែលជាប្រធាន។ ខ្ញុំបានផ្សព្វផ្សាយពាក្យនេះដល់សហសេវិកទាំងអស់”[៣០]។

---

[២៨] ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច ក្នុងកំណត់ហេតុនៃកិច្ចសួរយកចម្លើយ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ (“សំណុំរឿងលេខ 002/19-09-2007-ECCC-OCIJ, D13”) ទំព័រទី៣

[២៩] កំណត់ហេតុរបស់ កាំង ហ្កេកអ៊ាវ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ ទំព័រទី៥

C11/54

"ចម្លើយ: អំណាចរបស់ខ្ញុំគឺត្រឹមតែអនុវត្តតាមបញ្ជាថ្នាក់លើ និងផ្សព្វផ្សាយបញ្ជាទាំងនោះ ប៉ុណ្ណោះ មិនតិច ហើយក៏មិនលើសពីនេះដែរ។ នៅពេលដែលមន្ទីរស២១ត្រូវបានបង្កើតឡើង ការងាររបស់ខ្ញុំគឺត្រឹមតែអានឆ្លូវចម្លើយសារភាព និងរបាយការណ៍ជូន សុន សេនតាមទូរស័ព្ទ ជារៀងរាល់ថ្ងៃ។ នៅពេល សុន សេនមិននៅ ខ្ញុំជម្រាបទៅ នួន ជា ជារៀងរាល់ បី បួនថ្ងៃម្តង ឬយ៉ាងយូរណាស់ក្នុងរយៈពេល៥ថ្ងៃ។ ចំពោះអំណាចរបស់ខ្ញុំវិញ ខ្ញុំត្រូវផ្សព្វផ្សាយពាក្យពី ថ្នាក់លើ ទៅថ្នាក់ក្រោម និងធ្វើរបាយការណ៍ពីចម្លើយសារភាពទៅថ្នាក់លើវិញ។ [....] នួន ជា បាននិយាយថាខ្ញុំមិនចេះធ្វើការសោះ"[៣១]។

៥២. ក្នុងកំណត់ហេតុស្តួរយកចម្លើយរបស់ កាំង ហ្គេកអ៊ាវ ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៧ គាត់បាននិយាយទាក់ទងនឹងការ ចាប់ខ្លួនមនុស្សបួននាក់ក្នុងក្រុម Y៨ ហើយត្រូវបានបញ្ជូនទៅកាន់មន្ទីរស២១ ក្នុងអំឡុងខែមករាឆ្នាំ១៩៧៨៖

"[.....]ខ្ញុំបានសុំ នួន ជា ឱ្យទុកអ្នកទាំងបួននាក់នោះដើម្បីសួរចម្លើយ ហើយ នួន ជា បាននិយាយថា "សមមិត្តត្រូវតែម្ចាស់ការលើស្ថានការណ៍ហ្នឹង"។

[.....] នួន ជាបានសម្រេចកម្ទេចអ្នកទោសទាំងអស់ ប៉ុន្តែគាត់បានអនុញ្ញាតឱ្យខ្ញុំទុកអ្នកទោសទាំងបួននាក់នោះ ដោយគាត់បានប្រាប់ខ្ញុំថា "សមមិត្តត្រូវចាត់ចែងលើស្ថានការណ៍ដោយស្វ័យម្ចាស់ការ" ដែលមានន័យថាត្រូវកម្ទេចអ្នកទាំងនោះ នៅពេលចាំបាច់។ [.....]

សំណួររបស់ Francios Roux: តើយើងអាចនិយាយបានថា នួន ជាបានបញ្ជាលោក ហើយលោកបានបញ្ជាបន្តទៅអ្នកនៅក្រោមបង្គាប់របស់លោកតាមបញ្ជារបស់បក្ស ហើយអ្នកទាំងនោះបញ្ជាទៅពេជ្ឈឃាត ក្នុងន័យនេះតាមមុខនាទីរបស់ខ្លួន បុគ្គលម្នាក់ៗក្លាយជាអ្នកទទួលខុសត្រូវផ្ទាល់ក្នុងការអនុវត្តន៍សេចក្តីសម្រេចរបស់បក្ស?

---

[៣០] ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ក្នុងកំណត់ហេតុនៃកិច្ចស្តួរយកចម្លើយ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ ("សំណុំរឿងលេខ 002/19-09-2007-ECCC-OCIJ, D13") ទំព័រទី៣

[៣១] កំណត់ហេតុរបស់ កាំង ហ្គេកអ៊ាវ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ ទំព័រទី៧

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

C 11154

ចម្លើយៈ ពិតហើយ”[៣២]។

“សំណួររបស់ចៅក្រម ML: អញ្ជើង ជាធម្មតាលោកពិតជាអ្នកបញ្ជាឱ្យសម្លាប់មែនទេ?

ចម្លើយៈ ពិតហើយ។ ខ្ញុំសូមបញ្ជាក់ឱ្យបានច្បាស់បន្តិចៈ គ្រប់មន្ទីរសន្តិសុខទាំងអស់ដំណើរការដូចៗគ្នា។ មានន័យថា សេចក្តីសម្រេចធំធ្វើនៅកម្រិតមជ្ឈឹម។ ចំពោះមន្ទីរស២១ នួន ជា បានប្រាប់ខ្ញុំច្បាស់ណាស់ថាមនុស្សដែលបញ្ជូនមកទីនេះគឺត្រូវតែសម្លាប់។ ជាអ្នកទទួលខុសត្រូវមន្ទីរនេះ ខ្ញុំអនុវត្តតាមបញ្ជាទាំងនេះ។ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំមិនមានសិទ្ធិអំណាចលើមន្ទីរសន្តិសុខដទៃទៀតទេ”[៣៣]។

“សំណួររបស់ចៅក្រម យូ ប៊ុនឡេងៈ តើអ្វីទៅជាកំហុសចម្បងៗ ដែលនាំឱ្យគេចាប់ខ្លួន ហើយត្រូវបញ្ជូនមកមន្ទីរស២១? ប្រសិនបើប្រៀបធៀបជាមួយមន្ទីរសន្តិសុខដទៃទៀត តើវាខុសគ្នា ឬដូចគ្នាយ៉ាងដូចម្តេច? តើនរណាជាអ្នកសម្រេចឱ្យចាប់ខ្លួនអ្នកទាំងនោះពីក្រសួងស្ថាប័នផ្សេងៗនោះ?

ចម្លើយៈ អ្នកធ្វើសេចក្តីសម្រេចចិត្តមានពីរប្រភេទៈ ចំពោះសមាជិកនៃគណៈកម្មាធិការមជ្ឈិម សេចក្តីសម្រេចចិត្តត្រូវតែធ្វើឡើងដោយគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិម ។ ចំពោះអ្នកដទៃទៀត នួន ជា បានហៅប្រធានអង្គភាពពាក់ព័ន្ធមកពិភាក្សាជាមួយគាត់ ហើយពួកគេធ្វើសេចក្តីសម្រេចចិត្តរួមគ្នា”[៣៤]។

“សំណួររបស់ចៅក្រមយូ ប៊ុនឡេងៈ នៅពេលដែល សុន សេន ជាអ្នកទទួលខុសត្រូវ តើគាត់បានធ្វើដូចអ្វីដែល នួន ជា បានធ្វើឬទេ?

---

[៣២] ជនត្រូវចោទ កាំង ហ្គេចអ៊ាវ ក្នុងកំណត់ហេតុសួរយកចម្លើយលើជនត្រូវចោទ ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៧ សំណុំរឿងលេខ 002/19-09-2007-ECCC-OCIJ, D16 (“កំណត់ហេតុរបស់ ឌុច ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៧”) ទំព័រទី៣

[៣៣] កំណត់ហេតុរបស់ កាំង ហ្គេចអ៊ាវ ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៧ ទំព័រទី៤

[៣៤] កំណត់ហេតុរបស់ កាំង ហ្គេចអ៊ាវ ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៧ ទំព័រទី៥

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

ចម្លើយ: ខ្ញុំសូមរំលឹកប្រាប់លោកចៅក្រមថា សុន សេន នេះជាមនុស្សសំខាន់ទី៧ រីឯនួន ជា វិញគឺជាមនុស្សសំខាន់ទី២។ អ្វីៗត្រូវតែឆ្លងនួន ជាសិន បើទោះបីជាស្ថិតនៅក្នុងជួរយោធាក្តី។ [......] នួន ជា ជាមេរបស់សុន សេន"[៣៥]។

៥៣. នៅក្នុងសេចក្តីថ្លែងការណ៍របស់បក្សកុម្មុយនីស្តកម្ពុជា ទៅកាន់បក្សពលករកុម្មុយនីស្តរបស់ប្រទេសដាណឺម៉ាកនៅខែកក្កដា ឆ្នាំ១៩៧៨ នួន ជាបានថ្លែងថា៖

"បក្សរបស់យើងបានខិតខំអស់ពីកម្លាំងកាយចិត្ត និងបានរំដោះទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ..... បន្ទាប់ពីរំដោះបានភ្លាម យើងបានជម្លៀសប្រជាជនចេញពីទីក្រុង"[៣៦]។

៥៤. នៅក្នុងកិច្ចសម្ភាសន៍ជាមួយលោក ម៉េង ទ្រី, នួន ជា បាននិយាយថា៖

"ម៉េង ទ្រី:សួរ តើអ្វីទៅជាស២១? នួន ជា: ស២១ត្រូវបានបង្កើតឡើងដើម្បីស្វែងរកខ្មាំងរបស់ ប្រទេស។ ម៉េង ទ្រី: តើគេស្វែងរកខ្មាំងយ៉ាងដូចម្តេច? នួន ជា: ឆ្លើយ ស្វែងរកអ្នកណាដែលចង់ធ្វើបាបប្រជាជន។ មន្ទីរនេះត្រូវបានបង្កើតឡើងដើម្បីមើលការខុស ត្រូវលើបញ្ហានេះ ។ ក៏ប៉ុន្តែគួរឲ្យសោកស្តាយ នៅទីនោះមានកម្មាភិបាលអាក្រក់ ។ ម៉េង ទ្រី: សួរ តើគេមានបានរកឃើញខ្មាំងទេ? នួន ជា: គេពិតជាបានរកឃើញខ្មាំង។ ប៉ុន្តែកម្មា ភិបាលនៅស២១ បានធ្វើហួស ពីព្រំដែនសមត្ថកិច្ចរបស់ខ្លួន ។ ជួនកាលពួកគេមិនទាំង ធ្វើតាមផែនការផង ហើយពេលខ្លះ ពួកគេធ្វើហួសពីអ្វីដែលមានក្នុងផែនការ។ ឧទាហរណ៍ យើងឲ្យពួកគេធ្វើការត្រឹម៨ម៉ោង ពួកគេធ្វើការដល់១២ម៉ោង ។ យើងថាឲ្យ បាយទៅប្រជាជនហូប ពួកគេបែរទៅជាឲ្យប្រជាជនហូបតែបបរ ។ យើងឲ្យពួកគេធ្វើស្រែ ពួកគេមិនធ្វើ ។ យើងមិន

---

[៣៥] កំណត់ហេតុរបស់ កាំង ហ្កេចអ៊ាវ ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៧ ទំព័រទី៦

[៣៦] សេចក្តីថ្លែងការណ៍របស់នួន ជា ស្តីពីជនសង្ស័យរបស់បក្សកុម្មុយនីស្តកម្ពុជា សេចក្តីថ្លែងការណ៍របស់បក្សកុម្មុយនីស្តកម្ពុជាទៅកាន់បក្សពលករកុម្មុយនីស្តរបស់ប្រទេសដាណឺម៉ាក នៅខែកក្កដា ឆ្នាំ១៩៧៨ (ERN 00001170 - 00001185) ទំព័រទី៤-៥

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

បានយកចិត្តទុកដាក់ទៅលើកម្មាភិបាលជាន់ទាបហេតុដូច្នេះហើយ បានជារបបរបស់ពួកយើងបរាជ័យ”[៣៧]។

៥៥. ក្នុងខែធ្នូ ឆ្នាំ១៩៨៦ លោក ស្ទីវ ហ៊ីដឌឺហ៍ បានជួបសម្ភាសន៍ជាមួយលោក អៀង សារី ដែលពេលនោះបាននិយាយថា៖

“អៀង សារី: ថា ក្នុងខែកញ្ញា ឆ្នាំ១៩៧៥ មានកិច្ចប្រជុំមួយ ដែលបានសម្រេចថាតើយើងត្រូវតែធ្វើអ្វីខ្លះដើម្បីកុំឱ្យវៀតណាមយកប្រទេសកម្ពុជាបាន។

ស្ទីវ: សួរ ដូច្នេះ តើបញ្ហានេះត្រូវបានសម្រេចក្នុងកម្រិតគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស ឬក្នុងកម្រិតគណៈកម្មាធិការមជ្ឈិមបក្សទាំងមូល?

អៀង សារី: ឆ្លើយ ត្រឹមតែគណៈកម្មាធិការអចិន្ត្រៃយ៍តែប៉ុណ្ណោះ មិនមែនគណៈមជ្ឈិមបក្សទាំងមូលនោះទេ។

[.....] មែនទែនទៅ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ទាំងអស់មានវត្តមាននៅទីនោះ ពោលគឺ ប៉ុល ពត, នួន ជា, សោ ភឹម រូបខ្ញុំ [......][៣៨]។

“ស្ទីវ: តើការយល់របស់ខ្ញុំត្រឹមត្រូវឬទេ ដែលថាមានគណៈកម្មការអចិន្ត្រៃយ៍ ឬគណៈកម្មាការមជ្ឈិមមួយដែលទទួលខុសត្រូវរួមទាំងលើកិច្ចការសន្តិសុខផងនិងយោធាផង ពោលគឺស្ថិតនៅក្រោមអង្គការចាត់តាំងតែមួយ មិនមែនអង្គការចាត់តាំងពីរដាច់ដោយឡែកពីគ្នា?

អៀង សារី: ជាការត្រឹមត្រូវហើយ។ មានអង្គការចាត់តាំងតែមួយទេ ដែលទទួលខុសត្រូវលើកិច្ចការទាំងពីរនោះ។

---

[៣៧] កិច្ចសម្ភាសន៍របស់លោក ម៉េង ទ្រី ជាមួយ លោកខៀវ សំផន និងនួន ជា ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៦ (ERN 00000925-00000935) ទំព័រទី១០

[៣៨] កិច្ចសម្ភាសន៍របស់ ស្ទីវ ជាមួយនឹង អៀង សារី, ១៧ ធ្នូ ១៩៨៦ (ERN: 00003660-00003669) ទំព័រទី ២

00172968

C1/1154

ស្ទីវ: ហើយក្នុងអំឡុងពេលសង្គ្រាមរយៈពេល ៥ឆ្នាំ អង្គការចាត់តាំងនោះរួមមានសមាសភាព លោក ប៉ុល ពត នួន ជា សោ ភឹម តា ម៉ុក និងសុន សេន?
អៀង សារី: បាទ! ពិតប្រាកដណាស់!"[៣៩]

៥៦. កាលពីថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេតបានសួរយកចម្លើយលើលោក ខៀវ សំផន។ កំណត់ហេតុនៃការសួរយកចម្លើយមានដូចខាងក្រោម៖

"ជាគោលការណ៍ អង្គការចាត់តាំងដែលសំខាន់ជាងគេគឺគណៈកម្មាធិការមជ្ឈិម ប៉ុន្តែក្នុងការអនុវត្តន៍ជាក់ស្តែងអំណាចគឺស្ថិតក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍។ [.....] ដូច្នេះហើយ គណៈកម្មាធិការមជ្ឈិមមិនមានអំណាចពិតប្រាកដទេ បើប្រៀបធៀបនឹងគណៈកម្មាធិការអចិន្ត្រៃយ៍ ហើយនៅក្នុងគណៈកម្មាធិការនេះ បើតាមគោលកាណ៍ប្រជាធិបតេយ្យមជ្ឈការ នោះ មនុស្សដែលសំខាន់បំផុតគឺ លេខា និងអនុលេខាបក្ស ពោលគឺប៉ុល ពត និង នួន ជា។"[៤០]

៥៧. យោងតាមចម្លើយរបស់លោក មាស មុត អតីតលេខាតំបន់១៦៤ គាត់បាននិយាយនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០១ថា៖

"ខ្ញុំបានជួបជាមួយនួន ជា។ គាត់បានដើរគ្រប់កន្លែង[ក្នុងប្រទេស] ដើម្បីមើលស្ថានភាពរបស់ប្រជាជន"។[៤១]

៥៨. យោងតាមសក្ខីកម្មរបស់សាក្សី ជនត្រូវចោទគឺស្ថិតក្នុងឋានៈដែលអាចចេញបញ្ជាហើយជននេះបានប្រើឋានៈតួនាទីនេះដើម្បីបញ្ជាដល់បុគ្គលិកមន្ទីរស២១ ដែលឧក្រិដ្ឋកម្មជាច្រើនត្រូវបាន

---

[៣៩] កិច្ចសម្ភាសន៍របស់ ស្ទីវ ជាមួយនឹង អៀង សារី, ១៧ ធ្នូ ១៩៩៦ (ERN: 00003660-00003669) ទំព័រទី ៦

[៤០] ជនត្រូវចោទ ខៀវ សំផន ក្នុងកំណត់ហេតុសួរយកចម្លើយលើជនត្រូវចោទ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ សំណុំរឿងលេខ 002/19-09-2007-ECCC-OCIJ, D46 ទំព័រទី១០។

[៤១] សូមមើល កិច្ចសម្ភាសន៍ជាមួយ មាស មុត ដោយ គ្រីស្ទៀន នោរម៉ូ និងប៊ូ សារឿន (ERN 00089661-00089662) ទំព័រទី១

PRETRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

00172969

CL1/54

ប្រព្រឹត្ត ។ នេះអាចគ្រប់គ្រាន់ក្នុងការបង្ហាញអ្នកសង្កេត ដែលមិនលំអៀងបានថា ជនត្រូវចោទប្រហែលជាបានទទួលខុសត្រូវលើ ឬ បានប្រព្រឹត្តិឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ នៅក្នុងដំណាក់កាលនៃការស៊ើបអង្កេតនេះ។

ខ. **ការពិចារណាលើមូលហេតុដែលនាំឱ្យការឃុំខ្លួនបណ្តោះអាសន្ន ជាវិធានការណ៍ចាំបាច់ [វិធានផ្ទៃក្នុង វិធាន ៦៣(៣)(ខ)]**

*i. មូលហេតុទី១ និង ទី២ ក្នុងវិធានផ្ទៃក្នុង ៦៣(៣)(ខ) ចែងថា: ដើម្បី (i) ទប់ស្កាត់ជនត្រូវចោទកុំឲ្យដាក់ការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬទប់ស្កាត់មិនឲ្យមានការឃុបឃិតគ្នា រវាងជនត្រូវចោទ និងអ្នកសមគំនិតប្រព្រឹត្តិបទឧក្រិដ្ឋ ដែលស្ថិតនៅក្រោមយុត្តាធិការរបស់អ.វ.ត.ក និង(ii) ដើម្បីថែរក្សាភស្តុតាង ឬ រារាំងមិនឲ្យមានការបំផ្លាញភស្តុតាង* (វិធានផ្ទៃក្នុង ៦៣(៣)(ខ)(ii))

៥៩. ហេតុផលទាំងពីរនៃការឃុំខ្លួនបណ្តោះអាសន្នអាចយកមកវិភាគជាមួយគ្នា ពីព្រោះហេតុផលទាំងពីរនេះសម្អាងលើទឡ្ហីករណ៍ដូចគ្នា។ជាការពិតណាស់ ចម្លើយដែលសាក្សីផ្តល់ឱ្យអាចចាត់ទុកថាជា "ភស្តុតាង" ស្របតាមអត្ថន័យដែលមានចែងក្នុងវិធានផ្ទៃក្នុង៦៣(៣)(ខ)(ii)។

៦០. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សំណុំរឿងត្រូវបានគេរៀបចំសម្រាប់ជនត្រូវចោទដោយរួមបញ្ចូលទាំងឈ្មោះអ្នកដែលនឹងត្រូវធ្វើសាក្សីផង។ បើទោះបីជាសាក្សីទាំងនោះធ្លាប់បានផ្តល់ភស្តុតាង និងចម្លើយរួចហើយក្តី គេអាចកោះហៅសាក្សីទាំងនេះមកផ្តល់ចម្លើយឬសក្ខីកម្មម្តងទៀតក្នុងអំឡុងពេលនៃការស៊ើបអង្កេតក្រោយៗ និងក្នុងពេលសវនាការ។

៦១. អង្គបុរេជំនុំជម្រះយល់ឃើញថា ការសួរយកចម្លើយ កាំង ហ្គេកអ៊ាវ ដែលធ្វើឡើង ដោយសហចៅក្រមស៊ើបអង្កេត ផ្តល់នូវភស្តុតាងក្នុងដំណាក់កាលដំបូង ដែលតាមរយៈនេះ អង្គបុរេជំនុំជម្រះ សន្និដ្ឋានថា ជនត្រូវចោទរូបនេះធ្លាប់បានបំផ្លាញ "ភស្តុតាង" កាលពីអតីតកាល ហើយជននេះធ្លាប់បានស្តីបន្ទោស កាំង ហ្គេកអ៊ាវ ចំពោះការខកខានមិនបាន

E.C.C.C * C.E.T.C * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ធ្វើដូចខ្លួន ។ កំណត់ហេតុសួរយកចម្លើយលើជនត្រូវចោទ កាំង ហ្គេកអ៊ាវ មាន ខ្លឹមសារ ជាអាទិ៍ថា:

សំណួររបស់លោកMarcle Lemonde: *តើលោកត្រូវបានគេស្តីបន្ទោសឬទេ?*

ចម្លើយ: *បាទ។ នៅឆ្នាំ១៩៨៣។*

[...] នៅពេលនួន ជា ហៅខ្ញុំឱ្យទៅនិយាយគ្នា។ ដំបូងគាត់បានបន្ទោសខ្ញុំអំពីរឿង ដែលខ្ញុំបានទៅជួបខៀវ សំផន តែមិនទៅជួបគាត់។ នេះជាចំណុចដែលខ្ញុំបាននិយាយប្រាប់លោកចៅក្រមកាលពីព្រឹកមិញ។ ទីពីរ បន្ទាប់ពីគាត់បានសួរខ្ញុំរួចហើយ គាត់បានស្តីបន្ទោសខ្ញុំ ដោយនិយាយថា "សមមិត្តជាមនុស្សគ្មានបានការទេ។ ខ្ញុំបានបំផ្លាញឯកសាររបស់ខ្ញុំអស់ហើយ ប៉ុន្តែចំពោះសមមិត្តវិញបែរជាទុកឯកសារទាំងនោះទាំងគំនរ"[42]។

៦២. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញភ្លាមថា ចម្លើយទាំងនេះបញ្ជាក់ថាជនត្រូវចោទ អាចនឹងធ្វើការគំរាមកំហែងសាក្សី ឬព្យាយាមបំផ្លាញភស្តុតាង ទៅថ្ងៃអនាគត។ លើសពីនេះទៀត ពេលនេះសំណុំរឿងមានភស្តុតាង ដែលបង្កើតបានជាហេតុផលគួរឱ្យជឿជាក់បានថា ជនត្រូវចោទ មានមុខនាទីជាន់ខ្ពស់ក្នុងចលនាខ្មែរក្រហម ។ អង្គបុរេជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា តាមរយៈមុខតំណែងខ្ពស់នេះ ជនជាប់ចោទពិតជាមានអំណាចនិងឥទ្ធិពល ហើយឥទ្ធិពលនេះអាចនៅតែមាននៅឡើយរហូតមកដល់សព្វថ្ងៃនេះ។

៦៣. លើសពីនេះទៀត ទោះបីជាការចោទប្រកាន់នេះ សំដៅទៅលើព្រឹត្តការណ៍ ដែលបានកើតឡើងរយៈពេល ២៥ឆ្នាំ កន្លងផុតទៅហើយក្តី អង្គបុរេជំនុំជម្រះ ដោយពិចារណាអំពីការភ័យខ្លាចរបស់សាក្សីសក្តានុពលដែលនឹងត្រូវការផ្តល់ចម្លើយនៅចំពោះមុខ អ.វ.ក.ត[៤៣] យល់ឃើញថា

[៤២] កំណត់ហេតុសួរចម្លើយឌុច ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ ទំព័រទី៨។

[៤៣] Geerteke JASEN សម្លេងមកពីខេត្តតាកែវ: ការវាយតម្លៃសាកល្បងលើការភ័យខ្លាច ចំពោះការធ្វើជាសាក្សីក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ភ្នំពេញ មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ២០០៦) (ចម្លើយតបរបស់ព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃ ១៩ កញ្ញា ២០០៧ Annex A, Attachment A21

ប្រសិនបើមានការដោះលែងជនត្រូវចោទ ហើយបើជនរងគ្រោះបានដឹងអំពីរឿងនេះ អាចនឹងប៉ះពាល់ដល់ឆន្ទៈក្នុងការផ្ដល់សក្ខីកម្មប្រឆាំងនឹងជនត្រូវចោទ។

៦៤. អង្គបុរេជំនុំជម្រះបានយល់ឃើញថា សំណុំរឿងនេះមានផ្ទុកនូវហេតុផលគួរឲ្យជឿជាក់បានថា ជនត្រូវចោទអាចជាអ្នកទទួលខុសត្រូវលើបទឧក្រិដ្ឋ ដែលត្រូវបានចោទប្រកាន់ទាក់ទងនឹង មន្ទីរស២១។ សាក្សីដ៏តិចតួច ដែលដឹងពីហេតុការណ៍នៅមន្ទីរស២១ មានសារៈសំខាន់ណាស់សម្រាប់ការស៊ើបអង្កេត និងសម្រាប់អង្គជំនុំជម្រះ។ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា ការឃុំខ្លួនបណ្ដោះអាសន្នជាវិធានការណ៍ចាំបាច់ ដើម្បីរារាំងមិនឲ្យជនត្រូវចោទធ្វើការគាបសង្កត់លើសាក្សី ឬបំផ្លាញភស្តុតាង។

ii. *មូលហេតុទី៣ ក្នុងវិធានផ្ទៃក្នុង ៦៣(៣)(ខ): ដើម្បីធានាឲ្យមានវត្តមានរបស់ជនត្រូវចោទក្នុងកំឡុងពេលដំណើរការនីតិវិធី*

៦៥. អង្គបុរេជំនុំជម្រះសង្កេតឃើញថា បើតាមស្ថានទម្ងន់ទោសនៃបទចោទប្រកាន់ ជនត្រូវចោទអាចប្រឈមមុខនឹងទោសជាប់ពន្ធនាគារពី៥ឆ្នាំ ទៅមួយជីវិត ប្រសិនបើតុលាការរកឃើញថាគាត់មានពិរុទ្ធ។

៦៦. ទោះបីជាគេមិនអាចធ្វើការវាយតម្លៃពីហានិភ័យនៃការរត់គេចខ្លួន ដោយផ្អែកតែទៅលើស្ថានទម្ងន់ទោស និងទោសដែលអាចត្រូវទទួលក៏ដោយ អង្គបុរេជំនុំជម្រះសង្កេតឃើញថាក្នុងរឿងក្ដីនេះ កត្តាដទៃផ្សេងៗត្រូវតែលើកយកមកពិចារណាឲ្យបានគ្រប់ជ្រុងជ្រោយ។

៦៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ចម្លើយជាច្រើនរួមទាំងចម្លើយរបស់ជនត្រូវចោទផងនោះបង្ហាញថា លំនៅដ្ឋានរបស់ជនត្រូវចោទស្ថិតនៅជាប់ព្រំដែនប្រទេសថៃ។ ជនត្រូវចោទបានលើកឡើងពាក់ព័ន្ធនឹងបញ្ហានេះថា: "ប្រសិនបើខ្ញុំចង់គេចខ្លួន ខ្ញុំអាចគេចបានជាយូរមកហើយ។ តើខ្ញុំគេចទៅទីណា? ខ្ញុំអាចគេចទៅព្រំដែនប្រទេសថៃ ដោយគ្រាន់តែការដើ

C11/54

ដំណើរប៉ុន្មានជំហានប៉ុណ្ណោះ ។ ផ្ទះរបស់ខ្ញុំនៅជាប់នឹងព្រំដែន"[៤៤]។ បញ្ហាដែលថាជនត្រូវចោទមានកាន់លិខិតឆ្លងដែន ឬអត់នោះ មិនបានផ្លាស់ប្តូរឱកាសរបស់ជនត្រូវចោទក្នុងការធ្វើការឆ្លងដែនឡើយ វាគ្រាន់តែផ្លាស់ប្តូរឱកាសដែលថាតើនឹងត្រូវឆ្លងដែន កាត់តាមព្រំដែនមួយណាតែប៉ុណ្ណោះ។

៦៨. អង្គបុរេជំនុំជម្រះសង្កេតឃើញទៀតថា លំនៅដ្ឋានរបស់ជនត្រូវចោទស្ថិតក្នុងតំបន់ដែលគេស្គាល់ថាជាអតីតតំបន់ដែលមានការគាំទ្រខ្លាំងក្លារបស់ខ្មែរក្រហម ។ អង្គជំនុំជម្រះយល់ថាជនត្រូវចោទពិតជាមានទំនាក់ទំនងល្អនៅក្នុងតំបន់ព្រំដែន ហើយអាចមានខ្សែរយៈទំនាក់ទំនងរវាងព្រំដែនទាំងពីរ ដែលចូលរួមចំណែកក្នុងការផ្តល់លទ្ធភាពឲ្យជនត្រូវចោទក្នុងការរត់គេចខ្លួន។

៦៩. ចំពោះសេចក្តីអះអាងរបស់សហមេធាវីថា ជនត្រូវចោទធ្លាប់បានអះអាងជាសាធារណៈ និងស្របគ្នា អំពីឆន្ទៈរបស់គាត់ក្នុងការចូលរួមក្នុងដំណើរការនីតិវិធីនោះ អង្គបុរេជំនុំជម្រះយល់ឃើញថា មិនទាន់អាចជឿជាក់បាននៅឡើយទេ ពីព្រោះថារហូតមកដល់ពេលនេះជនត្រូវចោទបានអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបនៅឡើយ។

៧០. អង្គបុរេជំនុំជម្រះពិចារណាឃើញថា ការឃុំខ្លួនបណ្តោះអាសន្នជាវិធានការណ៍ចាំបាច់សម្រាប់ធានាឲ្យមានវត្តមានជនត្រូវចោទក្នុងកិច្ចដំណើរការនីតិវិធី។

***iii. មូលហេតុទី៤ ក្នុងវិធានផ្ទៃក្នុង ៦៣(៣)(ខ): ដើម្បីការពារសន្តិសុខរបស់ជនត្រូវចោទ***

៧១. ដោយពិចារណាទៅលើការរបាយការណ៍នៃការគំរាមកំហែងប្រឆាំងនឹង កាំង ហ្គេកអ៊ាវ កាលពីសវនាការជាសាធារណៈលើកទី១ នោះ ហើយបន្ទាប់ពីរកឃើញហេតុផលដែលគួរឲ្យជឿជាក់

---

[៤៤] សារព័ត៌មានភាសាអង់គ្លេស Teymoor Nabila, Aljazeera , ១៤ មិថុនា ២០០៧ "Meeting Brother number two" សារណាតបរបស់សហព្រះរាជអាជ្ញាចំពោះបណ្តឹងឧទ្ធរណ៍របស់ខ្លួន ជា ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ១៩ កញ្ញា ២០០៧, Annex B, Appendix K)

PRE-TRIAL CHAMBER * E.C.C.C. * C.E.T.C. * CHAMBRE PRÉLIMINAIRE

ថាជនត្រូវចោទបានប្រព្រឹត្តិឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ មានទំនាក់ទំនងទៅនឹងឧក្រិដ្ឋកម្មដែល កាំង ហ្គេកអ៊ាវ ត្រូវបានចោទប្រកាន់ អង្គបុរេជំនុំជម្រះយល់ឃើញថា កំហឹងទាំងនេះ អាចនឹងត្រូវបានគេបញ្ចេញដាក់ផងដែរចំពោះជនត្រូវចោទ[៤៥] ។

៧២. ទាក់ទងនឹងសេចក្ដីបញ្ជាក់របស់សហមេធាវីដែលថា ជនត្រូវចោទបានធ្វើសមាហរណកម្មចូលក្នុងសង្គមជាតិកម្ពុជាដោយសុខសន្តិភាពជិតដប់ឆ្នាំហើយនោះ ហើយក្នុងរយៈពេលកន្លងមកនេះមិនដែលមានអំពើហិង្សាណាមួយប្រឆាំងនឹងសេរីភាពរបស់គាត់ ឬ សកម្មភាពនៃការប៉ុនប៉ងសងសឹកអ្វីមួយលើរូបជនត្រូវចោទនោះឡើយ ។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ការដែលមិនមានការជ្រៀតជ្រែកទាំងនោះ អាចត្រូវបានកើតឡើងក្នុងបរិបទនៃនិរទោសដែលគ្រប់ដណ្ដប់មកអស់រយៈពេលជិត ៣០ ឆ្នាំ។ លើសពីនេះទៀត លំនៅដ្ឋានរបស់ជនត្រូវចោទស្ថិតក្រោមការឃាមកាម[៤៦] ។ ភាពចាំបាច់នៃឃាមកាមទាំងនេះ ជាការបង្ហាញដល់អង្គបុរេជំនុំជម្រះថា ពុំមានការធ្វើសមាហរណកម្មដោយសុខសន្តិភាព ដូចដែលសហមេធាវីបានលើកឡើងនោះទេ ។ ហើយតាមពិតទៅវាស្ដែងឲ្យឃើញថាជនត្រូវចោទខ្លួនឯង នៅមានការព្រួយបារម្ភចំពោះសុវត្ថិភាពផ្ទាល់ខ្លួននៅឡើយ។

---

[៤៥] កាសែត Cambodia Daily, Erika Kinetz និង Yun Samean, ២១ វិច្ឆិកា ២០០៧ “ឌុច ប្រឈមមុខនឹងចៅក្រមក្នុងសវនាការជាសាធារណៈលើកទី ១ របស់ អវតក” (សារណាតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្ដឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្នចុះថ្ងៃ ១៩ កញ្ញា ២០០៧, Annex A, Attachment A24)

[៤៦] កិច្ចសម្ភាសន៍របស់លោកខៀវ សំផន និងនួន ជា ដោយលោក ម៉េង ទ្រី នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៦ (ERB 00000925-00000935) លោកដុន ផាថាន់ (Don Phathan) *សារព័ត៌មាន Associated Press* ថ្ងៃទី៩ ខែមករា ឆ្នាំ១៩៩៩ “តំបន់កាន់កាប់របស់អតីតខ្មែរក្រហមបានក្លាយជាឋានសួគ៌របស់មេដឹកនាំ” ដុន ផាថាន់ (Don Phathan) សារព័ត៌មាន Associated Press ថ្ងៃទី៩ ខែមករា ឆ្នាំ១៩៩៩ (សារណាតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្ដឹងឧទ្ធរណ៍ របស់លោកនួន ជា ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃ១៩ កញ្ញា ២០០៧ ឧបសម្ព័ន្ធ ២) សារព័ត៌មានរស្មីកម្ពុជា ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៧ (សារណាតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃ១៩ កញ្ញា ២០០៧ ឧបសម្ព័ន្ធ ៦)

E.C.C.C * C.E.T.C * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

៧៣. អង្គបុរេជំនុំជម្រះយល់ឃើញថា ការឃុំខ្លួនបណ្ដោះអាសន្នជាវិធានការណ៍ចាំបាច់សម្រាប់ការពារសន្តិសុខរបស់ជនត្រូវចោទ។

*iv. មូលហេតុទី៥ក្នុង* **វិធានផ្ទៃក្នុង ៦៣(៣)(ខ):** *ដើម្បីរក្សាសណ្ដាប់ធ្នាប់សាធារណៈ*

៧៤. នៅក្នុងបណ្ដឹងឧទ្ធរណ៍នេះ សហមេធាវី និងសហព្រះរាជអាជ្ញាយល់ឃើញខុសគ្នាលើវិសាលភាពនៃសណ្ដាប់ធ្នាប់សាធារណៈ។ សហមេធាវីលើកឡើងថា ការឃុំខ្លួនដោយផ្អែកលើមូលហេតុសណ្ដាប់ធ្នាប់សាធារណៈ"ជាមូលហេតុដែលគេគួរលើកឡើងតែនៅពេលណា ដែលមានអង្គហេតុច្បាស់លាស់ និង នៅពេលណាដែលការឃុំខ្លួនគឺជាមធ្យោបាយដើម្បីបង្ក្រាបមិនឱ្យមានចលាចលប៉ុណ្ណោះ"[៤៧]។ សហព្រះរាជអាជ្ញាលើកឡើងថា យុត្តិសាស្ត្រដែលលើកឡើងដោយសហមេធាវីដើម្បីគាំទ្រកូនក្ដីរបស់ខ្លួន ជាពិសេសយុត្តិសាស្ត្រពីតុលាការសិទ្ធិមនុស្សអឺរ៉ុបមិនអាចយកមកអនុវត្តទាំងស្រុងនៅក្នុងករណីរឿងក្ដីឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅចំពោះមុខ អ.វ.ត.ក បានទេ ។ "តុលាការ ក្នុងស្រុក [...] អាចជាអ្នកសម្រេចថាតើ ការដោះលែងជនសង្ស័យពីបទចោទប្រកាន់លើឧក្រិដ្ឋកម្មក្នុងស្រុក ពិតជាអាចបណ្ដាលឱ្យមានបញ្ហាសណ្ដាប់ធ្នាប់សាធារណៈនៅក្នុងតំបន់ ឬយ៉ាងណា ។ ប៉ុន្តែ អ.វ.ត.កស្ទើរតែមិនអាចស្មានបានទាល់តែសោះ ថាតើការដោះលែងជនត្រូវចោទ ពីបទចោទប្រកាន់លើឧក្រិដ្ឋកម្មអន្តរជាតិ ពិតជាអាចបណ្ដាលឱ្យមានបញ្ហាសណ្ដាប់ធ្នាប់សាធារណៈនៅក្នុងប្រទេសមួយ ដែលមានប្រជាជនរាប់លាននាក់នោះបាន ឬអត់នោះទេ"[៤៨]។

៧៥. វិធានផ្ទៃក្នុងមិនមានការបកស្រាយអំពីបញ្ហានេះទេ។ យោងតាមមាត្រា ១២ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្ដីនៅក្រោម

[៤៧] បណ្ដឹងឧទ្ធរណ៍របស់នួន ជា ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ កថាខណ្ឌ...។

[៤៨] សារណាតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្ដឹងឧទ្ធរណ៍របស់លោកនួន ជា ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧, ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៧ កថាខ័ណ្ឌ៣៥។

00172975

CMI/54

ច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ[49] អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា លក្ខន្តិកៈ និងវិធាននៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិក៏មិនមានចែងពីបញ្ហាដែលស្រដៀងគ្នានេះដែរ។ មាត្រា ២១(៣) នៃលក្ខន្តិកៈក្រុងរ៉ូម នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ICC ចែងថា "ការអនុវត្ត និងការបកស្រាយច្បាប់អនុលោមតាមមាត្រានេះត្រូវតែ ស្របទៅតាមសិទ្ធិមនុស្សដែលទទួលស្គាល់ជាអន្តរជាតិ[50] ។ ដោយពិចារណា អំពីភាពពាក់ព័ន្ធជាក់ស្តែងក្នុងប្រទេសនីមួយៗស្តីពីមូលដ្ឋាននេះ និង ពិចារណាទៅលើមាត្រា ២១(៣) នៃ លក្ខន្តិកៈក្រុងរ៉ូម អង្គបុរេជំនុំជម្រះយល់ឃើញថា វាជាការសមរម្យណាស់ ដែលត្រូវស្វែងរកការណែនាំបន្ថែមពីច្បាប់យុត្តិសាស្ត្រនៃតុលាការសិទ្ធិមនុស្សអឺរ៉ុប។

៧៦. នៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួន សហមេធាវីបានលើកឡើងអំពីករណីរឿងក្តីរបស់ Letetllier។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នៅក្នុងករណីមួយនេះ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានពិចារណាឃើញថា "អង្គហេតុដែលធនល្មមក្នុងការបង្ហាញថា ការដោះលែងជនជាប់ចោទ ដែលអាចរំខានដល់សណ្តាប់ធ្នាប់សាធារណៈត្រូវតែមាន ។ លើសពីនេះទៀត ការឃុំខ្លួននឹងនៅតែបន្តស្របច្បាប់ លុះត្រាតែមានការគំរាមកំហែងលើសណ្តាប់ធ្នាប់សាធារណៈយ៉ាងពិតប្រាកដ [...]"[51]។

៧៧. អង្គបុរេជំនុំជម្រះយល់ឃើញថា ពេលវេលាកន្លងផុតទៅមិនទាន់លុបបំបាត់ឥទ្ធិពលនៃរបបកម្ពុជាប្រជាធិប្បតេយ្យមកលើសង្គមកម្ពុជាបច្ចុប្បន្ននៅឡើយទេ។ គេជឿជាក់ថា មនុស្សមួយចំនួនដែលបានរស់នៅឆ្លងកាត់របបនេះពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ នៅតែទទួលរងនូវជំងឺបាក់ស្បាតនៅឡើយ។ អ្នកឯកទេសបានបញ្ជាក់ថា ការចាប់ផ្តើមសកម្មភាពតុលាការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អាចធ្វើឲ្យមានហានិភ័យថ្មីទៀតដល់សង្គម

[49] មាត្រា ១២ នៃកិច្ចព្រមព្រៀង រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់ កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ, ២០០៣

[50] លក្ខន្តិកៈក្រុងរ៉ូម នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ, ១៧ កក្កដា ១៩៩៨

[51] ECHR រឿងក្តី Letellier v. France, ២៦ មិថុនា ១៩៩១ កថាខណ្ឌ ៥១

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

00172976

CMI/54

កម្ពុជា"។ វាអាច "នាំឲ្យមានការកើតឡើងវិញនៃភាពភ័យខ្លាច និងផលវិបាកជាអវិជ្ជមានក្នុងសង្គម"[52]។

៧៨. មហាសន្និបាតនៃអង្គការសហប្រជាជាតិបានទទួលស្គាល់ថា ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិប្បតេយ្យពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នៅតែជាបញ្ហាដែលគួរឲ្យបារម្ភសម្រាប់សង្គមកម្ពុជា និងមនុស្សជាតិទាំងមូល។

> បើរំលឹកអំពីការរំលោភបំពានដ៏ធ្ងន់ធ្ងរទាំងទៅលើច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ យើងឃើញថាបញ្ហានេះ នៅតែជាកង្វល់ដ៏ធំមួយសម្រាប់សហគមន៍អន្តរជាតិទាំងមូលតែម្តង,
>
> [...]
>
> ដោយទទួលស្គាល់ថា ការទទួលខុសត្រូវរបស់ជនដែលបានប្រព្រឹត្តបទល្មើសនៃការរំលោភបំពានធ្ងន់ធ្ងរដល់សិទ្ធិមនុស្ស គឺជាធាតុផ្សំសំខាន់សម្រាប់ជាមធ្យោបាយដ៏មានប្រសិទ្ធិភាពមួយដើម្បីសងជម្ងឺចិត្តដល់ជនរងគ្រោះ [...][53]

៧៩. សវនាការលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ បានទាក់ទាញការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់ប្រជាពលរដ្ឋកម្ពុជា និងសារព័ត៌មាន និងសហគមន៍អន្តរជាតិ។ មានមនុស្សរាប់រយនាក់ មានទាំងសាធារណៈជន តំណាងអ្នកសារព័ត៌មាន អង្គការក្រៅរដ្ឋាភិបាល និងទាំងសហគមន៍អន្តរជាតិផង បានចូលរួមក្នុងសវនាការ។ ការចាប់អារម្មណ៍បែបនេះ គឺសញ្ញាណនៃការពិតមួយដែលបញ្ជាក់ឲ្យឃើញថា ការជំនុំជម្រះក្តីមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តទៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ

[52] Rob Savage, Monthly South Eastern Globe, "Post Traumatic Stress Disorder: A Legacy of Pain and Violence" កក្កដា ២០០៧, ទំព័រ ២៤-២៧ (ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃ ១៩ កញ្ញា ២០០៧, Annex A, Attachment A25)

[53] Preamble, Resolution adopted by the General Assembly-Khmer Rouge Trials, GA Res A/RES/57/228, ២៧ កុម្ភៈ ២០០៣

ចាប់ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ មិនថាក្នុងដំណាក់កាលមុនអង្គសេចក្តីទេ គឺនៅតែជាក្តីកង្វល់ដ៏ធំមួយនាពេលបច្ចុប្បន្ននេះ សម្រាប់ប្រជាពលរដ្ឋខ្មែរជាទូទៅ និងសម្រាប់សហគមន៍អន្តរជាតិផងដែរ។

៨០. អង្គបុរេជំនុំជម្រះបានសង្កេតឃើញបន្ថែមទៀតថា ការគំរាមកំហែងដល់បញ្ហាសន្តិសុខគឺពិតជាមានមែន។ ទីមួយគឺវាបង្ហាញឱ្យឃើញច្បាស់តាមរយៈបញ្ហាអន្តិសុខដែលកើតមានជារៀងរាល់ថ្ងៃ ឬតាមរយៈបទឧក្រិដ្ឋហឹង្សាផ្សេងៗទៀត ដែលអង្គបុរេជំនុំជម្រះមើលឃើញថាវាជាការពិតមួយដែលមនុស្សគ្រប់គ្នាបានដឹងឮជាទូទៅ។ ទីពីរ ឧទាហរណ៍នៃកុប្បកម្មប្រឆាំងថៃក្នុងឆ្នាំ២០០៣ ចង្អុលយោងទៅរកលទ្ធភាព ដែលអាចជំរុញឱ្យមានអស្ថេរភាពខាងនយោបាយបាន។[54]

---

[54] John Aglionby, The Guardian, ៣១ មករា ២០០៣, "ថៃផ្តាច់ទំនាក់ទំនងជាមួយកម្ពុជាបន្ទាប់ពីមានកុប្បកម្ម" (ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងដីកា សម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃ ១៩ កញ្ញា ២០០៧, Annex A, Attachment A15) សារព័ត៌មាន BBC ១០ កុម្ភៈ ២០០៣ " Thai diplomats return to Cambodia" (ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងដីកា សម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃ ១៩ កញ្ញា ២០០៧, Annex A, Attachment A16) CNN.com ៣០ មករា ២០០៣ " Cambodia apologizes for riots" (ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងដីកា សម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃ ១៩ កញ្ញា ២០០៧, Annex A, Attachment A17), Michael Flint, Evaluation of DFID Country Programmes, Country Study: Cambodia 1997-2003, ទំព័រ 4 (ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងដីកា សម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃ ១៩ កញ្ញា ២០០៧, Annex A, Attachment A19) Human Rights Watch and Amnesty International, ១១ កុម្ភៈ ២០០៣ , "Cambodia: Freedom of expression under attack" (ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងដីកា សម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃ ១៩ កញ្ញា ២០០៧, Annex A, Attachment A20), US Department of State, Bureau of East Asian and Pacific Affairs, Report to Congress on the Anti-Thai Riots in Cambodia នៅថ្ងៃ ២៩ មករា ២០០៣, ១៤ ឧសភា ២០០៣ (ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងដីកា សម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃ ១៩ កញ្ញា ២០០៧, Annex A, Attachment A26)

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

00172978



៨១. អង្គបុរេជំនុំជម្រះយល់ឃើញថាអង្គហេតុដូចដែលពោលខាងលើ គឺអាចធន់ល្មមក្នុងការបង្ហាញបានថា ការដោះលែងជនត្រូវចោទ គឺអាចនឹងធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈជាប្រាកដ ។ ដូច្នេះអង្គបុរេជំនុំជម្រះរកឃើញថា ការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នគឺជាវិធានការណ៍ចាំបាច់មួយដើម្បីរក្សាសណ្តាប់ធ្នាប់សារណៈ។

**ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ**

៨២. សហមេធាវីបានលើកឡើងថា ក្នុងចំណោមកង្វល់ទាំងឡាយដែលសហចៅក្រមស៊ើបអង្កេតបានលើកឡើង គឺគ្មានចំណុចណាមួយដែលអាចយកមកធ្វើជាការពិតបាន ដើម្បីបញ្ជាក់ថាប្រសិនបើគេដោះលែងជនត្រូវចោទ នោះគាត់នឹងត្រូវប្រឈមមុខនឹងស្ថានភាពដូចដែលបានសហចៅក្រមស៊ើបអង្កេតបានគិតទុកនោះឡើយ។ ដូច្នេះហើយទើបបានជាសហមេធាវីយល់ថាតុលាការគួរតែដោះលែងជនត្រូវចោទដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការនោះ។

៨៣. អង្គបុរេជំនុំជម្រះរកឃើញថា ក្នុងរឿងក្តីនេះ លក្ខខណ្ឌទាំងឡាយនៃវិធាន ៦៣(៣) (ក) និងមូលដ្ឋានទាំងប្រាំដូចមានចែងក្នុងវិធាន ៦៣(៣)(ខ) គឺត្រូវបានបំពេញរួចរាល់។ ហើយការបំពេញបានត្រឹមតែលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងនេះ ក៏អាចមានលក្ខណៈគ្រប់គ្រាន់ដើម្បីយកមកធ្វើជាសំអាងក្នុងការឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្នបានដែរ។ នេះមានន័យថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការណ៍ចាំបាច់ដើម្បីធានា សន្តិសុខសាក្សី និងជនត្រូវចោទ ដើម្បីថែរក្សាភស្តុតាង ដើម្បីធានាការបង្ហាញខ្លួនជនត្រូវចោទក្នុងកិច្ចដំណើរការនីតិវិធី និងដើម្បីថែរក្សាសណ្តាប់ធ្នាប់សាធារណៈ។ ក្នុងកាលៈទេសៈបែបនេះ អង្គបុរេជំនុំជម្រះពិចារណាឃើញថា ជនត្រូវចោទមិនអាចដោះលែងឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការបានឡើយ ដោយហេតុថាលក្ខខណ្ឌទាំងឡាយដែលជនត្រូវចោទបានស្នើឡើង គឺមិនសំខាន់ជាងភាពចាំបាច់នៃការឃុំខ្លួនគាត់ជាបណ្តោះអាសន្នឡើយ។

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER * CHAMBRE PRÉLIMINAIRE
E.C.C.C * C.E.T.C

C1/54

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទៈ:**

១) បណ្តឹងឧទ្ធរណ៍អាចទទួលយកបានតាមទម្រង់

២) សហចៅក្រមស៊ើបអង្កេត បានអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួនត្រឹមត្រូវ ក្នុងការចេញដីកាឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ

៣) មូលដ្ឋានសម្រាប់ការឃុំខ្លួនបណ្តោះអាសន្ន នៅតែមានលក្ខណៈគ្រប់គ្រាន់

៤) តម្កល់ដីកាឃុំខ្លួនរបស់សហចៅក្រមស៊ើបអង្កេត ហើយមូលហេតុដែលបញ្ជាក់ក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបានជំនួសដោយមូលហេតុដែលបានបញ្ជាក់ក្នុងសាលដីកានេះ

៥) បដិសេធចោលបណ្តឹងឧទ្ធរណ៍

សាលដីកានេះបិទផ្លូវតវ៉ា អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង។

សាលដីកានេះ **ប្រកាសជាសាធារណៈ** ដោយអង្គបុរេជំនុំជម្រះ នៅចំពោះមុខជនត្រូវចោទ និងសហមេធាវីរបស់ជនត្រូវចោទ។

ភ្នំពេញ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

Rowan DOWNING **នេ យ ថុល** Katinka LAHUIS **ហួត វុធី** **ប្រាក់ គឹមសាន**

**ក្រឡាបញ្ជីសវនាការ**

**កែវ ទានី** Dirk Jan LAMAM